រៀបរៀងចងក្រង
ស៊ូ-ចំរើន

ឯកសារ
ប្រវត្តិសាស្ត្រ

# អាចារ្យស្វា



ប្រវត្តិតស៊ូនៃវីរបុរសខ្មែរក្នុងសតវត្សទី១៩

# អាចារ្យស្វា



ប្រវត្តិតស៊ូនៃវីរបុរសខ្មែរក្នុងសតវត្សទី១៩

# អារម្ភកថា

ខ្ញុំបានឯកសារជាច្រើនដែលនិយាយទាក់ទងនឹងអាចារ្យស្វា ។ ទោះឯកសារនោះជាភាសាជាតិក្តី ជាភាសាបរទេសក្តី ច្រើនតែឃើញថា អាចារ្យស្វាជាមនុស្សក្បត់ជាតិ ។ ហេតុបានជាឯកសារទាំងនោះចាត់ទុក អាចារ្យស្វាជាមនុស្សក្បត់ជាតិ ? សំនួរនេះ ខ្ញុំអាចឆ្លើយថា ព្រោះ ពេលនោះខ្មែរនៅក្រោមអាណាព្យាបាលបរទេស តែនរណាម្នាក់មិនពេញ ចិត្តនឹងការត្រួតត្រាពួកបរទេស អ្នកនោះត្រូវ អ្នកអាណាព្យាបាលចោទថា ជាអ្នកក្បត់ជាតិ ម្លោះហើយការសរសេរត្រូវតែថា <<ក្បត់ជាតិ>> តាម តែគ្នា ។

ខ្ញុំបានជួបឯកសារមួយទៀត ដែលកំចាំងនឹងភ្នែកបរទេស ដែល អ្នកសរសេរបានទុកនៅជាមួយខ្ញុំ ហើយអ្នកសរសេរនោះត្រូវជាញាតិរបស់ អ្នកបាញ់អាចារ្យស្វាស្លាប់ទៀតផង ។ អ្នកបាញ់អាចារ្យស្វាស្លាប់ ជាអ្នកឱ្យ ឯកសារខ្ញុំនេះសរសេរ គាត់ជាអ្នកហៅឱ្យសរសេរតាម ។ ឯកសារនេះ មិនឃើញមានថាអាចារ្យស្វាក្បត់ ខ្ញុំតែងបានជួបចាស់ៗ និយាយតាម ស្រុក ភូមិ ថា អាចារ្យស្វាជាមនុស្សស្នេហាជាតិ ។ ហើយមកដល់ សម័យសាធារណរដ្ឋនេះ គណៈកម្មការក្រុងបានសម្រេច យកឈ្មោះ អាចារ្យស្វា ដាក់ឈ្មោះផ្លូវនៅរដ្ឋធានីភ្នំពេញនេះទៀតផង ។ នេះសរឱ្យ ឃើញថា អាចារ្យស្វាគាត់ជាមនុស្សបដិវត្តន៍មួយសម័យប្រទេសនៅ ជាអាណាព្យាបាល

សម័យសាធារណរដ្ឋនេះ ជាសម័យដែលគួរស្រាវជ្រាវ វីរបុរសដែលគេចោទថា មនុស្សក្បត់ឱ្យឃើញមានពន្លឺយុត្តិធម៌ដូចជា អាចារ្យស្វា ពោកំបោរជាដើម ឱ្យយុវជនបានដឹងផង ។ ខ្ញុំសង្ឃឹមថា រឿងអាចារ្យស្វា ដែលនៅក្នុងដៃលោកអ្នកអាននេះ ទោះបីមិនបានគ្រប់គ្រាន់ ក៏ជាពន្លឺបន្តិចដែរ ហើយខ្ញុំសូមផ្ញើទុកឯកសារដែលខ្វះសូមឱ្យលោកអ្នកអានជួយរកបន្ថែមទៀតផង ។

ម្យ៉ាងទៀតបន្ទាប់ពីអាចារ្យស្វានេះទៅខ្ញុំបានសរសេរ រួចស្រេចនូវប្រវត្តិ ឬ ជីវភាពអ្នកស្នេហាជាតិដ៏ក្លាហានក្នុងសង្គ្រាមប្រឆាំងនឹងមរទេសដូចជាពញា **ហូទ** តេជោក្រហមក, តេជោយ៉ត, ម៉ឺនមាស, ពិស្ណុលោកឈូក, នរាប្រាក់ នៅខេត្តព្រៃវែង ហើយបន្ទាប់ពីនេះខ្ញុំកំពុងរកប្រវត្តិលោក តេជោប៉ាង, តេជោចាប, តេជោជូ តទៅទៀត ។ រឿងអាចារ្យស្វានេះខ្ញុំបានសរសេរចប់នៅចុងឆ្នាំ ១៩៦៨ ហើយបានបោះពុម្ពផ្សាយនៅក្នុងសារពត៌មានយុវជនម្តងរួចទៅហើយ

រៀបរៀងចងក្រង

ដោយ **ស៊ូ ចំរើន**

# ១

## ចាបឧកញ៉ាចិន្ត្រោសុខ

គេហដ្ឋានមួយខ្នងប្រក់ក្បឿង ដែលមានដើមស្វាយមានមែកសាខា ហើយនិងរុក្ខជាតិផលព្រឹក្សដទៃទៀតជាច្រើនដុះជិតស្ទើរតែរកមើលផ្ទះមិនឃើញ ។ ក្រៅពីរុក្ខជាតិដែលមាននៅក្នុងភូមិ គេឃើញមានរោងសេះ ក្រោលគោច្រើនទៀតនៅក្បែរគៀនរបង ។ រោងសេះមួយនៅឈៀងខាងជើងក្បែររបងប្រក់ស្បូវ គេមិនឃើញមានសេះទេ ព្រោះតាជ-នេយ្យជាម្ចាស់រោងនេះ ត្រូវជូនចៅហ្វាយទៅធ្វើការ ផ្ទុយទៅវិញ គេឃើញមាន់៣-៤កំពុងតែចឹកកកាយលាមកសេះៗ បក្សីទាំងនេះ កំពុងតែចឹករកអាហារចំណី ស្រាប់តែផ្អើលភិលឡើង ដោយស្មានថាសត្វរបស់ខ្លួនមកឲ្យរំខានក្នុងការស្វែងរកចំណី ។ លោកស្រីជាម្ចាស់ផ្ទះឮស្នូរមាន់ផ្អើលផ្ទូះ ក៏ដើរតាមបង្អួចដែលមានជន្ទល់មួយ ទល់ទ្របង្អួចឲ្យហើប

ឡើង រកមើលហេតុប្ដូរស្រូវដែលចូលមកក្នុងរបង តែមិនឃើញមានសោះ ឃើញតែសេះដែលជូនចៅហ្វាយប្រុសទៅកាន់មន្ទីរធ្វើការត្រឡប់មកខុសកាល ហើយឃើញបាវរបស់គាត់កំពុងតែបង់សេះក្នុងរោង ។ លោកស្រីឃើញបាវមកខុសកាលតែម្នាក់ឯងដូច្នេះ ក៏ស្រែកសួរទាំងភ័យថា :

– ដីស្វា ! ឯណាឃើញលោកប្រុស ?

– ប្របាទលោកស្រី ! ខ្ញុំបាទរត់មកមុន ដើម្បីជំរាបលោកស្រីឲ្យបានជ្រាបថា លោកប្រុសមិនបានអញ្ជើញមកផ្ទះទេក្នុងថ្ងៃនេះ

– លោកនៅឯណា ?

– ប្របាទនៅឯកេនជំនុំឯណោះ

នាយស្វានិយាយផងឡើងផង ហើយដើរទៅជិតលោកស្រីសុខ អង្គុយបត់ជើងលើក្ការលោនស្រលនៅក្បែរចៅហ្វាយស្រី

– ដីស្វា ម៉េចបានជាលោកក្រុមការម៉ុះក្នុងថ្ងៃនេះ ?



– ប្របាទ ! ខ្ញុំបាទមិនបានដឹងរឿងអ្វីទេ តែលោកប្រុសឲ្យខ្ញុំបាទមកជំរាបលោកស្រីមុន កុំឲ្យលោកស្រីភ័យ ដោយមិនឃើញលោកប្រុសអញ្ជើញមកតាមពេលធម្មតា

– អើចុះដីស្វាឯងមិនឮលោកនិយាយពីអ្វីខ្លះទេ ព្រោះនៅកំពង់មាន . . .

– អូលោកស្រី ! ខ្ញុំបាទឮដែរ តែមិនមែនលោកប្រុសនិយាយទេ

– ឲ្យតែឮ តើគេនិយាយថាម៉េចខ្លះ ?

– ប្របាទ ខ្ញុំឮគេនិយាយខ្លះដែរថា ឧកញ៉ាស្រីធម្មា-ធិកជ ប៊ុឥ (១) ដែលទៅឈរក្បាលបន្ទាយក្នុងពេញ បាននាំពលសេនាជាច្រើនទៅដេញកំចាត់ពួកកំហែងក្រៅ ៗ ទ័ពទាំងពីរបាញ់តទល់គ្នាអស់ពេលជាយូរ តែទីបំផុត ទ័ពខាងកំហែងក្រៅ បាក់បបខ្ចបខ្ចាបទៅវិញទៅ ហើយនាំគ្នារត់ខ្ចាត់ខ្ចាយបែកបាក់ពួកអស់ ៗ

(១)– ឯកសារផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ ។

— អ៊ីចុះទ័ពឧកញ៉ាស្រីធម្មាធិកជ ប៊ុត ចាប់វាំមិនបានខ្លះទេឬ ?

— ប្របាទ ទ័ពលោកឧកញ៉ាចាប់វាំមិនបានទេ ព្រោះវាដឹងមុន ពួកវានាំគ្នារត់គេចផុតពីទ័ពឧកញ៉ាស្រីធម្មាធិកជទៅ តែគេចរួចពីទ័ពនេះ ទៅចូលសឹងទ័ពឧកញ៉ាធម្មាតេជោ ញឹម

— មែនហ្ន៎ ! ទេវតាមិនដែលបម្រើនឲ្យសោះ ៗ អ៊ីចុះជីស្វាឯងមានឮគេនិយាយដូចម្តេចទៀតទេ ?

— ទ័ពកំហែងកែវ ដែលគេចពីទ័ពឧកញ៉ាស្រីធម្មាធិកជ ហើយមកជួបនឹងទ័ពឧកញ៉ាធម្មាតេជោ ញឹម ហើយត្រូវទ័ពឧកញ៉ាធម្មាតេជោ បាញ់សម្លាប់អស់ជាច្រើន ឯខ្លួនកំហែងកែវ ក៏ស្លាប់ដែរ ៗ

— អុញហ្ន៎ ! មែនហ្ន៎ តែក្បត់ជាតិមុខតែអាយុខ្លី

— លោកស្រីអស្ចារ្យណាស់ គេថា រូបកំហែងយោធា កែន នោះ ត្រូវគេកាត់យកតែក្បាលយកមកឧត្តុង្គ ហើយគេថា ថ្ងៃល្ងាចបន្តិចទៀតមកដល់ឧត្តុង្គហើយ ៗ គេប្រកក្បាល



កំហែងយោធា កែន ក្នុងជាល ហើយមុខតែយកមកកាត់មុខផ្ទះយើងហ្នឹង សូមលោកស្រីរង់ចាំមើលចុះមុខតែឃើញមិនខាន

— ណៃជីស្វា នរណាខ្លះដែលចូលដៃជាមួយកំហែងយោធានោះ ?

— ខ្ញុំបាទមិនបានដឹងទេ ឮតែទាហាននិយាយអ៊ឹះ ៗ ស្តាប់ច្បាស់ខ្លះ មិនច្បាស់ខ្លះ តែដឹងជាងគេតែកំហែងយោធា កែន ហ្នឹងជាងគេ ហើយខ្ញុំបាទដូចជាឮថាលោកហោរ ឡាយ ក៏ជាអ្នកចូលដៃរួមដែរ ៗ លោកស្រីមានស្គាល់លោកនោះឬទេ ?

— ឮតែឈ្មោះ

— ប្របាទលោកហោរ ឡាយ ហ្នឹងហើយ មុខតែជាអ្នកខួលក្បាលកំហែងយោធា កែន ៗ សូមលោកស្រីចាំពិនិត្យឲ្យឃើញច្បាស់ចាំងហោរ ឡាយ ផងទៅ ៗ លោកស្រីមិនយូរប៉ុន្មានទេ មុខតែមកដល់មុខផ្ទះយើងមិនខានឡើយ

គេយកទៅថ្វាយព្រះអង្គទត ហើយយកទៅដើរស្រែកអា-
ក្រោសឯផ្សារឯណោះទៀត ។

— ដីស្វាឯងមានឮឈ្មោះមហារិទ្ធិវង្គ ស្ទួន ឬទេ ?

— ប្របាទ ដូចជាឮឈ្មោះថា ស្ទួន ៗ ដែរ តែមិនដឹងជាអាសេក្តិគេដូចម្តេច ហើយមួយទៀតឈ្មោះនេះពិបាកនឹងចាំផង ចាំតែត្រឹមស្ទួ ៗ តែមានឈ្មោះស្ទួមួយទៀតត្រូវគេចាប់បានដែរ ។

— ចុះឥឡូវឈ្មោះ ស្ទួន នោះ ឮថាគេយកទៅណា ?

— ប្របាទឮគេនិយាយថា ស្ទួន អីនោះ គេចាប់បានដាក់ទ្រុង ដើម្បីយកមកថ្វាយព្រះរាជាទាំងរស់ តែមិនទាន់បានយកមកផង ស្រាប់តែឮថា វាបាក់ទ្រុងរត់ទៅណាបាត់ តាមរកមិនទាន់ឃើញ ។

— ស្លាប់ហើយ ឲ្យតែវារត់រួចមុខតែវាប្រព្រឹត្តហួសដើមទៅទៀត ព្រោះអីវានេះខ្លាំងពូកែស្រាប់ផង

— លោកស្រី! ខ្ញុំបាទឮគេនិយាយថែមទៀតថា ឈ្មោះ



ស្ទួន នេះ រត់ចេញពីទ្រុងរួចទៅ បានទៅជួបនឹងគូកនដែលសុទ្ធតែជាពួកប្រឆាំងដូចគ្នា ៗ លុះប្រមូលគ្នាបានហើយធ្វៀតនូវឱកាសយប់បន្ទាប់មក ទៅសម្លាប់ឧកញ៉ាជំរុំធិបតី ស្ទួស ស្លាប់ទៅទៀត

— មែនថា ការនេះតែសម្លាប់វាមិនបានហើយ មុខតែវាបែរមកក្រោយវិញហើយ ដូចជាខ្លាដែលត្រូវមួយព្រនង់អ៊ីចឹងដែរ ។ អ៊ីចុះឥឡូវមានឮថាគេចាត់ឲ្យទ័ពទៅតាមចាប់វាទៀតឬទេ ?

— ប្របាទការនេះ ខ្ញុំបាទមិនបានដឹងឮថាដូចម្តេចទៅទៀតដែរ ព្រោះគេឃើញខ្ញុំបាទ គេចេះតែឈប់និយាយ ដែលឮបន្តិច ៗ នេះ ព្រោះគេមិនធ្លាប់ស្គាល់ខ្ញុំបាទ ។

ដីស្វានិយាយបានតែប៉ុណ្ណោះ ក៏ចុះទៅវិញ ព្រោះត្រូវយកសេះទៅជូនចៅហ្វាយប្រុសនៅឯកេងប្រជុំឯណោះ ៗ ដីស្វាចុះទៅបានពាក់កណ្តាលជណ្តើរ ស្រាប់តែនឹកឃើញរឿងមួយទៀត ក៏បែរមកជំរាបលោកស្រីថា :

– លោកស្រី ខ្ញុំបាទជំរាបលោកស្រីមិនទាន់អស់ ។ ខ្ញុំបាទឮថា ឈ្មោះ ស្នួន សម្លាប់ឧកញ៉ាដំរុងគិរីបតី ស្នួស ហើយប្រមូលបក្សពួកទៅចូលជាមួយបារាំងនៅឯកេនដំរីឯណោះ (១)

– ឃើញទេ អានេះវាក្បត់ វាគិតទៅចូលជាមួយបរទេស ព្រោះវាអស់សង្ឃឹមនឹងចូលមកទ័ពជាតិវិញ ។ អានេះគោលបំណងវាមិនគិតតែរំលំកដបល្អក្តៃតែម្យ៉ាង ។ តែជីស្លាឯងកុំភ្លេចណា តែនរណាក្បត់នឹងជាតិឯង មុខតែទេវតាបំផ្លាញជីវិត ឬក៏ធ្វើឲ្យអ្នកក្បត់វិនាសជីវិតមិនខាន ។

– មែនលោកស្រី ពួកនោះនាំគ្នាទៅសុំចុះចូលបម្រើបារាំង តែដល់បារាំងដឹងថា ពួកនោះសុទ្ធតែជាពួកក្បត់នឹងស្តេចព្រះនរោត្តម ទើបនាំគ្នាចាប់ឈ្មោះ ស្នួន ឧកញ៉ាពជតេជះ **ហាយ** ស្នង ត្រឹម នឹងពួកគូកនដទៃទៀត យកទៅដាក់តោលឯកោះត្រឡាច (២) ឯណោះព្រះអើយ

---

១– ពង្សាវតារសរសេរដៃ ភាគ ៣ ទំព័រ ៨៧០ ។

២– ពង្សាវតារសរសេរដៃ ភាគ ៣ ទំព័រ ៨៨០ ។



– អើស្រេចទៅចុះ ឲ្យវាទៅសោយកម្មនៅឯកោះត្រឡាចចុះ ។

– លោកស្រី ខ្ញុំបាទទៅទទួលលោកប្រុសហើយ

នាយស្លាទៅទទួលចៅហ្វាយវិញ ចិត្តចេះតែភ្ញើតភ្ញើន ដល់ឮថាស្នួនត្រូវវិនាសជីវិត ក៏នាយស្លាឈប់គិតរឿងនោះទៅវិញ ព្រោះហាក់ដូចជាខ្លាចបាត់ជីវិតដែរ ។ រឿងមួយរយជំពូករត់ចូលមកក្នុងខួរក្បាលនាយស្លាហួតដល់សេះនាំទៅកាន់ទីដៅដល់ ទើបជីស្លាភ្ញាក់រលឹកពីតាសភាពនៃការយល់សប្តិ ។

លោកឧកញ៉ាវិជ្ជាសុខ រួចកិច្ចការប្រជុំការងារហើយ ទើបត្រឡប់មកវិញ ។ លោកមានសេចក្តីរីករាយណាស់ ព្រោះកិច្ចការសម្រាប់នគរ បានដោះស្រាយថ្វាយព្រះបាទសម្តេចព្រះនរោ[illegible]បរមគរការរួចស្រេចហើយ ។ លោកត្រឡប់មកផ្ទះវិញ ក៏មិនបាននិយាយរឿងអ្វីឲ្យភរិយាដឹងពីការងារដែលជំនុំដែរ ព្រោះលោកយល់ច្បាស់ថា ការនយោបាយស្រុកទេសមិនត្រូវឲ្យប្រពន្ធដឹងទេ ។ កន្លងមកមិនយូរប៉ុន្មាន

នៅខែចេត្រ ឆ្នាំចត្វាស័ក ព.ស. (១) មាន មនុស្សពិការម្នាក់(២) ទៀតឈ្មោះ **ស្មុនសឡាំ** តាំងចេញប្រ-ឆាំងនឹងរាជបល្ល័ង្កដែរ បានទៅបញ្ចុះបញ្ចូលរាស្ត្រស្រុកស្រែចំការបានជាច្រើន ។ **ស្មុនសឡាំ** ជាមនុស្សពិការដៃជើង តែដោយមានពួកបរិវត្តិ៍ចូលរួមផង មកលើក **ស្មុនសឡាំ** ជាមនុស្សមានរិទ្ធិ ហើយនៅវេលាយប់ ពួកនោះនាំគ្នាយក **ស្មុនសឡាំ** និងប្រពន្ធកូនរត់ទៅនៅខាងជើងភ្នំព្រះរាជទ្រព្យ ។ **ស្មុនសឡាំ** ឲ្យមេបក្ស មេគង ចេញទៅកេណ្ឌកជាទ័ពបាន ហើយ នាំគ្នាចំរុងលើកចូលទៅលុកកំពង់ឧត្តុង្គមានជ័យ តែខុ-កាសមិនហុចឲ្យ ទើប **ស្មុនសឡាំ** ឲ្យបោះកងទ័ពនៅព្រៃក្រាំងខ្នុរ(៣) ក្បែរខេត្តសំរោងទងសិន ។ រៀបកងទ័ពឲ្យបាននៅស្រួលបន្តិចហើយ **ស្មុនសឡាំ** ចាត់ឲ្យសេភា **ប៉ែន** នាំទ័ពឲ្យទៅបាញ់បង្អើលទ័ពសម្ដេចព្រះនរោត្តម ដែលនៅឯកំពង់ឧត្តុង្គ

១ — ពង្សាវតារសរសេរដៃ លេខ ៧ ទំព័រ ៤៨០ ។ ២ — សកភាពនេះ បាន បញ្ជាក់តាមសៀវភៅបញ្ជាក់សកភាពលោក ភួង-ខួន ហើយ ។ ៣ — ពង្សាវតារសរសេរដៃ លេខ ៧ ទំព័រ ៤៨១ ។



មានជ័យ ជាច្រើនលើកច្រើនផង ។

មុនកើតហេតុនេះឡើង ចារបុរសខាងសម្ដេចព្រះនរោត្តម បានរាយការណ៍ឲ្យដឹងមានមុន ទើបព្រះអង្គទ្រង់ចាត់ឧក-ញ៉ានរិន្ទនាយក **អ៊ុំ** ថា :

— លោកនរិន្ទនាយក **អ៊ុំ** ខ្ញុំអញ្ជើញលោកមកនេះដើម្បីចាត់លោកឲ្យចំពេញមុខងារជួនរាជបល្ល័ង្កនៅថ្ងៃស្អែកនេះ ខ្ញុំបានពត៌មានតាមចារបុរសរបស់យើងថា ទ័ព **ស្មុនសឡាំ** ចាត់ឲ្យសេភា **ប៉ែន** មកលបបាញ់បង្អើលយើង ។ ឥឡូវយើងដឹងមុន សូមលោកលើកទ័ពទៅចាំស្ទាក់ទ័ពសេភា **ប៉ែន** កុំឲ្យវានាំទ័ពរត់រួច ។

— ទូលព្រះបង្គំនឹងចាត់ការទ័ពចំរើនរាជបល្ល័ង្កតាមព្រះរាជបញ្ជាដោយពេញចិត្ត ។

— អើសូមលោកលើកទ័ពទៅឲ្យបានជោគជ័យ ។

— សាធុ !

ឧកញ៉ានរិន្ទនាយក **អ៊ុំ** លើកទ័ពទៅចាំព័ទ្ធស្ទាក់កុំឲ្យទ័ព

សុភា ម៉ែន ចូលមកឈានពានបាន ។ ទ័ពសុភា ម៉ែន ចូលមកបាញ់បានតែបន្តិច ៗ ស្រាប់តែនរិន្ទនាយក រ៉ុង បញ្ជាឲ្យទ័ពបាញ់តសម្រុកចូលទៅទ័ពបដិវត្តន៍ បែកបាក់ទ័ពរត់ចោលគ្នាលែងមើលក្រោយ ។ បន្ទាប់ពីការកើតហេតុនោះបន្តិចមក នៅព្រះបរមរាជវាំងឧត្តុង្គមានជ័យ ពេលយប់ជ្រៅណាស់ហើយ នៅមិនទាន់ឃើញពន្លត់ភ្លើងនៅឡើយទេ ។ ឯចាហ្វានយាមវាំង ឃើញតែនៅឈរយាមគ្រប់ទ្វារ មិនមានធ្វេសប្រ-ហែសឡើយ ។ យូរ ៗ គេឮសូរវាយត្រដោកផ្លាស់យាមវេនគ្នាម្តង ៗ នៅយប់នោះ ឧកញ៉ាវិជ្ជា សុខ ក៏បានទៅរួមប្រ-ជុំដែរ តែលោកមិនស្រួលខ្លួន លោកក៏ក្រាបថ្វាយបង្គំលាព្រះមហារាជ ត្រឡប់ទៅគេហដ្ឋានមុនទៅ ។ នៅទីបំផុតនៃការជុំនុំសម្ងាត់មក សម្តេចព្រះនរោត្តម ទ្រង់មានព្រះរាជបញ្ជាឲ្យឧកញ៉ាធម្មាធិរាជ ប៊ុក[១] ឲ្យធ្វើជាសម្តេចចៅពញា ហើយត្រាស់ប្រើចក្រី កែប លើកទ័ពទៅតាមព័ទ្ធចាប់ទ័ពសុនស-

១— ពង្សាវតារសរសេរដៃ ភាគ ៣ ទំព័រ ៨៨១ ។



ញ៉ា ។ ឯទ័ព សុនសញ៉ា ដឹងដំណឹងថា ទ័ពល្បួងចេញទៅហើយ ក៏នាំកងទ័ពរត់ទៅដល់ខេត្តពោធិសាត់ ។ សម្តេចចៅពញា ប៊ុក ឧកញ៉ាចក្រី កែប ឧកញ៉ានរិន្ទនាយ រ៉ុង លើកទ័ពចេញទៅតាមប្រកិត ៗ និងទ័ព សុនសញ៉ា ទៅរួមជាមួយនឹងក្រុមការងារចៅហ្វាយស្រុកពោធិសាត់ ក៏ចោមចាប់ សុនសញ៉ា បានទាំងអស់ ។ ក្រុម សុនសញ៉ា និងគ្រួសារ ត្រូវកងទ័ពចាប់បញ្ចូលទៅជាពលរឹបទាំងអស់ ហើយនាំ សុនស-ញ៉ា យកមកថ្វាយព្រះមហាក្សត្រនៅឯឧត្តុង្គមានជ័យ ។ សុ-នសញ៉ា មកដល់ពាក់កណ្តាលផ្លូវឈឺចិត្តណាស់ ក៏ក្ស័យជីវិតទៅ ។ កងទ័ពនាំយកសព សុនសញ៉ា មកដល់ឧត្តុង្គមានជ័យហើយ សម្តេចព្រះនរោត្តមឲ្យសែងស្រែកតាក្រោស ៣ ថ្ងៃ ហើយឲ្យនាំយកទៅដោតត្កាងនៅឯផ្លូវថ្នាខាងលិចចឹងផ្សារដែក ដើម្បីទុកជាបំរាមចំពោះប្រជារាស្ត្រដែលមានចិត្តករត់ទឹងរាជបល្ល័ង្ក ។

**ស្វនសង្ហាំ** ស្លាប់ទៅជាមួយបក្សពួកពិតមែន តែអ្នកដែលបង្កចលាចលស្ទើរតែគ្រប់ខេត្ត មិនថាតែខ្មែរទេ បើបែរទៅមើលខាងស្វាយទង, ត្រាំង ជាដើម ពួកយួនឈ្លានពានចូលមកសង្កត់សង្កិនរាស្ត្រនៅទីនោះ បង្កចលាចល គ្មានស្រាកស្រាន្តសោះ ។

# ២

## អាចារ្យស្វាក្លែងឈ្មោះ

ចលាចលកើតមានកាន់តែច្រើនឡើងៗ ម្ល៉ោះហើយតែល្ងាចបន្តិច គេឃើញគេហស្ថានខ្លះបិទទ្វាររបងទៅហើយ ។ ថ្ងៃនេះ គេហដ្ឋានលោកឧកញ៉ាវិជ្ជា **សុខ** នៅមិនទាន់បិទទ្វាររបងទេ ព្រោះអ្នកដែលជាទ្វារបាលនោះ មិនទាន់ឃើញត្រឡប់មកពីក្រៅ ។ លោកឧកញ៉ាវិជ្ជាឃើញទ្វារចំហដូច្នោះ ទើបសួរដណ្ដឹងទាសីនៅក្នុងផ្ទះ :

– **អាចែម !**

– ចាស៎

– ណែមកណេះ

មីង **ចែម** ជាបំរើលោកឧកញ៉ាវិជ្ជា **សុខ** ក៏រត់សរវៃមកជួបចៅហ្វាយ ស៊ូទុកការងារដែលមិនទាន់ហើយពាលមួយកន្លែងសិន ។

– តើ ចេខ ចេញណោះហើយនៅមិនទាន់បិទទ្វាររបង អ៊ុ ចុះជីស្វាទៅណាទៅ ?

– ជំរាបប្រសាសន៍ មិនដឹងជាទៅណាដែរ គ្រាន់តែយកសេះមកចងហើយ ខ្ញុំឃើញចេញទៅក្រៅវិញទៅ

– ឥឡូវ ចេខ ឯងទៅបិទទ្វារទៅ

មីង ចេខ ចុះទៅប្រុងនឹងបិទទ្វារ ទៅដល់ទ្វាររបងស្រាប់តែជួបនឹងជីស្វាមកដល់ដែរ ដូច្នេះមីង ចេខ ក៏ទុកការៈនេះឲ្យទៅម្ចាស់គេធ្វើទៅវិញ ។ ជីស្វាបិទទ្វារហើយ ទៅបិទទ្វាររោងសេះទៀត ទើបឡើងទៅលើផ្ទះដោយតាំងបុកសង្ហារមុខក្រហមដូចត្រូវគេតដូរ ។ លោកស្រីឧកញ៉ាវិជ្ជា **សុខ** ឃើញអាការៈប្លែកដូច្នេះ ក៏សួរថា :

– ជីស្វា ថ្ងៃនេះដូចជាមិនសប្បាយ មានកើតអ្វី ?

– ប្របាទ ! គ្មានកើតអីទេ

– អ៊ីចុះម៉េចបានតែក្រហមមុខម៉្លេះ ?

– ប្របាទ ខ្ញុំបាទទៅឃ្វាលសេះ បានជួបមនុស្សបំ



ប្លែកម្នាក់មកពីព្រំង ៗ គេនិយាយប្រាប់រឿងនៅឯព្រំនឹងណោះថា យួនចូលមកសង្កិនសង្កត់ខ្មែរច្រើនណាស់ ៗ រាចូលមករឹបអូសយកទ្រព្យសម្បត្តិ រាសម្លាប់អ្នកស្នេហាជាតិ ៗ ខ្ញុំឮដូច្នេះហើយ បានជាក្រហមមុខ ក្រហមមុខដោយទោសៈទឹងបរទេសចូលមកជិះជាន់ខ្មែរ ៗ ខ្ញុំដឹកសេះយកមកផ្ទះ ឃើញថ្ងៃនៅភ្លឺនៅឡើយ ខ្ញុំបាទក៏ស្ទាក់ទៅរកជួបមនុស្សបំប្លែកនោះទៀត ដើម្បីសួរឲ្យដឹងដើមដឹងចុង តែទៅដល់កន្លែងនោះ ស្រាប់តែរកមិនឃើញ ៗ

– រឿងប៉ុណ្ណឹងទេឬ ?

– បាទ

តាំងពីជីស្វាបានជួបមនុស្សបំប្លែកនោះ ជីស្វាចេះតែមានអាកប្បកិរិយាប្លែកឡើងរាល់ថ្ងៃ ៗ

នៅតែប៉ុន្មានថ្ងៃទៀតនឹងចូលឆ្នាំថ្មី នៅក្រុងឧត្តុង្គអ្នកភូមិកំពុងតែលើកថ្កល់ ជំរះស្មៅ បោសសំអាតគេហដ្ឋាន ឯជីស្វាបោសសំអាតគេហដ្ឋានលោកឧកញ៉ាវិជ្ជាហើយ ក្មៀត

ទៅមើលបងរបស់ឲ្យបានដាច់ត្រឹមត្រូវ ។ លោកស្រីសុខ ឃើញដូច្នោះ ចេះតែលួចសរសើរក្នុងចិត្តថា "ចាំចូលឆ្នាំរួចទើប ទៅភ្ជាប់ពាក្យកូនអ្នកព្រែកឲ្យជាគូដណ្តឹងដីស្វា" ។ លោកស្រីក៏បានជំរាបស្វាមីថា :

– បងដល់ចូលឆ្នាំហើយគិតទៅភ្ជាប់ពាក្យដីស្វានឹងកូនអ្នកព្រែកទៅ ដើម្បីឲ្យបានមុនចូលវស្សា ខ្ញុំគិតបងរៀបទុកដាក់រួចហើយទៅ ។

– ស្រេចតែឯងគិតទៅចុះ បងមានការរវល់ច្រើនណាស់ ។

ការសន្យានោះបានតែត្រឹមណឹងក៏បាត់ទៅ ព្រោះមានបំរើមកពីវាំងឲ្យមកអញ្ជើញលោកឧកញ៉ាវិជ្ជា សុខ ទៅគាល់ព្រះនរោត្តម ។

មុនចូលឆ្នាំមួយថ្ងៃ ធាតុអាកាសក្តៅថ្ងែក សត្វមាន់ខ្លះកំពុងតែកកាយដីហើយដេកត្រដាងស្លាបនៅក្រោមដើមល្មុតៗ ពេលថ្ងៃលិចទៅហើយ ធាតុអាកាសក៏នៅមិនទាន់ត្រជាក់



ណាស់ណាទេ លោកស្រី សុខ អង្គុយចាំមើលស្វាមីផង ចាំមើលដីស្វាផង មិនយូរប៉ុន្មាន ស្រាប់តែឃើញលោក សុខ ត្រឡប់មកវិញ ។

– ម៉េចបានជាមកអង្គុយនឹងកាំជណ្តើរដូច្នេះ ?

– ចាស ចាំមើលបង ហើយនឹងដីស្វា

– ថ្មើរណេះហើយដីស្វាមិនទាន់មកទេ ?

– ចាស មិនទាន់មកទេ ។

– បើថ្មើរណេះនៅតែមិនទាន់ឃើញវាត្រឡប់មក សូមកុំគិត វាមុខតែលែងនៅនឹងយើងហើយ ។

– ថាម៉េច ?

– វាឈប់នៅជាមួយយើងហើយ ។

– ចុះវាទៅណា ?.

– នរណាដឹង តែបងថាដូច្នេះ ព្រោះគេឃើញវាជិះសេះយើងទៅហួសភូមិឃុំស្បែកទៅហើយ តាំងពីថ្ងៃរសៀលម៉្លេះ ។

- បើដូច្នោះ ខ្ញុំដឹងហើយ

- ឯងដឹងដូចម្តេច ?

- វាតែងនិយាយថា វាការណិតក្រស្នានៅស្រុកត្រាំងណាស់ ព្រោះក្រស្នានៅកន្លែងនោះ យួនបេះតែមកសង្កត់សង្កិនដុតបំផ្លាញផ្ទះសម្បែង ហើយមុនចូលឆ្នាំប្រហែល៨ថ្ងៃទៅនេះ វាបានជួបមនុស្សប្រែខ្សែកម្នាក់ មកនិយាយរឿងយួនដែលធ្វើបាបខ្មែរនៅបាក់ខ្ទះ នៅមាត់ជ្រូកខ្លះ នៅស្រុកត្រាំងខ្លះ ៗ បើតាមខ្ញុំយល់ វាច្បាស់ជាទៅបង្កទ័ពនៅឯត្រាំងមាត់ជ្រូកហើយ ដើម្បីដេញទ័ពយួនឲ្យចេញពីត្រាំង ៗ

- ណែ ! ឯងកុំមាត់ សព្វថ្ងៃគេកំពុងតែបង្ក្រាបមនុស្សដែលបង្កចលាចល ៗ

- ចុះវាមានទៅបង្កចលាចលឯណា ព្រោះនៅកន្លែងនោះមានចលាចលស្រាប់ទេតើ វាគ្រាន់តែទៅប្រមូលខ្មែរឲ្យគេតាំងប្រឆាំងដេញទ័ពឈ្លានពានរំលោភទឹកដីទេតើ ក្រែងសព្វថ្ងៃលួងកំពុងតែបង្ក្រាបចលាចលថ្ង បើបានវាបង្ក្រាបហើយ គួរ



តែសរសើរវា ៗ

- ស្អីក៏ដោយឯងកុំទៅគិត ទ័ពកងការមាន ម៉េចមិនទៅចូល ?

- ខ្ញុំមិនដឹងទេរឿងនេះ

- បើមិនដឹងនៅតែស្ងៀមទៅ

ការជជែកគ្នាមិនបានការអ្វី ស្វាមីភរិយាក៏ឈប់ទៅ ឯភរិយាឡើងទៅរៀបអាហារភោជនជូនស្វាមី ៗ ព្រឹកឡើងថ្ងៃរះផុតចុងឈើទៅហើយ គេឃើញលោកស្រីសុខ ប្រើទាសីឲ្យយកសេះទៅចងស៊ីស្មៅនៅមុខផ្ទះ ៗ នាងទាសីចេញផុតពីរបងបន្តិច ស្រាប់តែខុចង៉ក់ ដោយឃើញមនុស្សជិះសេះយ៉ាងលឿនបំបោលមកពីចម្ងាយ នាងមិនបានចងសេះទេ នៅឈរទ្រឹងកាន់ខ្សែសេះ ៗ អ្នកជិះសេះកាន់តែមកជិតទើបនាងស្គាល់ថា អ្នកជិះសេះគឺជាចៅហ្វាយប្រុសរបស់នាង ៗ លោកឧកញ៉ាវិជ្ជាសុខ លោតចុះពីខ្នងសេះមក ហើយប្រគល់សេះឲ្យទាសីឈ្មោះចេង ហើយឡើងទៅលើ

ផ្ទះយ៉ាន់លឿន ដើម្បីទៅរកជួបករិយាគាត់ ។

— ម៉េចបានជាឪកាជិតមកវិញ ?

— បងបានពត៌មានច្បាស់ណាស់ពីដីស្វា ដូច្នេះហើយ បានជាបងត្រឡប់មកវិញ ដើម្បីឲ្យម៉ែកាជិតដឹងផង ។ គេឲ្យការមកថា ដីស្វាដែលគេបចេញពីផ្ទះយើងទៅ វាទៅកំពត មែននៅឯបាត្ក៏ វាប្រកាសបញ្ចុះបញ្ចូលរាស្ត្របានច្រើនណាស់ ដោយវាបានប្រាប់រាស្ត្រប្រជាថា វាជាព្រះអង្គតិម ។

— ស្លាប់ហើយ ម៉េចបានជាវាហ៊ានយកព្រះនាមព្រះរាជបុត្រ ព្រះឧបរាជព្រះអង្គអិម នោះទៅក្លែងដូច្នោះ ក្រែងព្រះអង្គតិម ត្រូវជាព្រះរាជបុត្រព្រះអង្គអិម មែនឬ ?

— ហ្នឹងហើយ ! ម៉ែកាជិតនៅមិនទាន់យល់ទេ

— ខ្ញុំយល់ដែរ តែវាមិនច្បាស់ ខ្ញុំដឹងថាព្រះអង្គអិម មានព្រះរាជបុត្រាមួយព្រះនាមព្រះអង្គតិម ។

— អ៊ីចុះចាំស្តាប់ណ៎ា ។ នៅឆ្នាំ១៨២៥(១) ព្រះជាយា

១— Le Royaume du Cambodge page 107 par J Moura.



របស់ព្រះឧបរាជព្រះអង្គអិមប្រសូត្របុត្រមួយព្រះអង្គនៅស្រុកសៀមហើយថ្វាយនាមថា ព្រះអង្គតិម ។

— ខ្ញុំមិនដឹងថាព្រះអង្គអិម មានព្រះរាជបុត្រអង្គតិមនៅឆ្នាំណាទេ តែដឹងថាអង្គតិម ត្រូវជារាជបុត្រនៃព្រះអង្គអិម ។

— បើម៉ែកាជិតឯងមិនដឹងទេ ចាំស្តាប់ខ្ញុំសិនទៅណ៎ា កុំកាលនិយាយកាត់ ព្រោះបងប្រញាប់ត្រឡប់ទៅវិញៗ ព្រះអង្គអិមមានព្រះជន្ម២០វស្សា គឺនៅឆ្នាំ១៨៤៥ ឧបរាជព្រះអង្គអិម សុគតនៅស្រុកកូសាំងស៊ីន(១) ។ ព្រះអង្គមានរាជបុត្រតែមួយព្រះអង្គគត់ គឺអង្គតិម ។

— ចុះក្រែងឥឡូវ ព្រះអង្គតិមសុគតទៅហើយមែនទេ ?

— អើនៅឆ្នាំ១៨៤៨(២) ព្រះរាជាទ្រង់បញ្ជូនព្រះរាជ-បុត្របួននិងព្រះអង្គតិមឲ្យទៅសិក្សានៅបាងកក ។ តែឥឡូវព្រះអង្គសុគតទៅហើយ ហើយដីស្វាវាទៅយកព្រះនាមរបស់

១— Le Royaume du Cambodge page 117 par J Moura.

២—Le Royaume du Cambodge page 127 par J Moura.

ព្រះអង្គទៅប្រាប់ប្រជាកស្ត្រថា វាហ្នឹងហើយជាព្រះអង្គ គឹម ទើបត្រឡប់មកពីស្រុកសៀម ។ ប្រជាកស្ត្រឮថាព្រះរាជវង្ស ចេញកសាងជាតិដូច្នេះ ចុះចូលយ៉ាងសម្បើមគោរពបូជាគ្មានគិតឡើយ ហើយចុះចូលដោយគ្មានសង្ស័យថា វាជាដីស្លាឡើយ ។ តាមពិត ព្រះអង្គ គឹម ក្រោយមកគង់នៅបាងកក មានព្រះរោគវិកលចរិត ហើយព្រះអង្គសុគតទៅនៅបាងកក ក្នុងព្រះជន្ម ៣១ វស្សា[១] មានតាំងរៀបបូជាព្រះសពយ៉ាងឧឡារិកផង ។

— អ៊ីចុះរឿងដីស្លាវាទៅដូចម្តេចទៅឲ្យគាជិត ព្រោះវាជាទាសៈរបស់យើង នរណាក៏គេថាវាជាចំរើរបស់យើង ហើយឥឡូវវាទៅចំបះចំបោរដូច្នេះ ក្រែងមានរឿងដល់យើងណា ?

— ចាបង់ភ័យហើយ បានជាខ្ញុំមកប្រាប់ម៉ែវាឲ្យដឹង តែរឿងនេះ ព្រះរាជាទ្រង់ជ្រាបស្រេចហើយ បានជាព្រះអង្គទ្រង់សួរបញ្ជាក់ថា វាជាទាសៈរបស់យើងមែន ។ បងទូល

១– ពង្សាវតារសរសេរដៃ ភាគ ៣ ទំព័រ ៨៤៤ ។



តាមត្រង់ តែព្រះអង្គធ្វើហាក់ជាព្រងើយ ដូចជាមិនចាប់ភ្លឹកពីរឿងដីស្លា ។

— អ៊ីចុះ មែនតែព្រះអង្គទ្រង់ជ្រាបការណ៍នេះអស់ទៅហើយ យើងជាត្រកូលដែលស្មោះស្ម័គ្រនឹងព្រះរាជបល្ល័ង្ក ។

— អើម៉ែវា កុំតែបានប៉ុណ្ណេះ ម៉្លេះយើងមិនដឹងជាទៅដល់ណាទេ ។ តែនិយាយពីរឿងរាជបល្ល័ង្ក បងគួរទ្រូងដូចដកបន្លាចេញពីទ្រូងដែរ ព្រោះថានរណាដែលយករាជបល្ល័ង្កមកជាឡប់ឡែ ច្រើនតែរួចខ្លួន ។ ម៉ែវា បងព្រួយណាស់ កាលៈទេសៈនេះ វាចេះតែប្រែប្រួលដូច្នេះហើយ សូម្បីតែមនុស្សខ្ជិនក្រនែងក្រង់ក៏ចេះធ្វើជាមេបះដែរ ។

លោកឧកញ៉ាវិជ្ជាសួន ប្រាប់ភរិយាចប់សព្វគ្រប់ ក៏ត្រឡប់ទៅព្រះរាជវាំងវិញ ។ មិនទាន់តាំងអស់រឿងផង គាត់ក៏ចេញទៅ ព្រោះគាត់ក្រែងមានការអ្វីនៅឯព្រះបរមរាជវាំង គាត់ចុះទៅដល់ដី ស្រាប់តែទឹកឃើញរឿងទៀត គាត់ក៏ឡើងមកវិញ ។

— ក្រែងនុកជាប្រញាប់ទៅវាំងឬ ?

— តែបងនឹកឃើញរឿងមួយទៀត មុនបងមកនេះបន្តិច មានសំបុត្រមួយមកពីពេនជ័រ (តែនិញ) ថា មានលិខិតមួយសរសេរទៅបាវាំងជាភាសាខ្មែរ ហើយបាវាំងឈ្មោះ អាមីរ៉ាល់ ដឺឡាគ្រង់ឌីយេ (Amiral de la Grandier) [១] ផ្ញើមកឯវាំងថា :

> ខ្ញុំអង្គគីម ជាព្រះរាជបុត្រនៃព្រះអង្គអឹម ទើបតែយាងត្រឡប់មកពីស្រុកសៀម ។ ខ្ញុំសរសេរចុតហ្មាយមកនេះ ដើម្បីចង់ជួបជាមួយលោក ជាពិសេស បើសិនជាលោកឲ្យខ្ញុំជួប សូមលោកផ្ញើលិខិតតបមកខ្ញុំវិញ តាមបុរសដែលយកលិខិតមកជូនលោកនេះ ។
>
> សូមអរគុណទុកជាមុន
>
> ព្រះហត្ថលេខា អង្គគីម
>
> ត្រាំង ខែ សីហា ឆ្នាំ ១៨៦៤

១— Le Royaume du Cambodge page 151 par Moura.



លិខិតនេះ ត្រូវបាន អាមីរ៉ាល់ ដឺឡា គ្រង់ឌីយេ ផ្ញើទៅព្រះនរបតី នៅឯព្រះបរមរាជវាំងឧត្តុង្គមានជ័យរួចទៅហើយ ។

— ម៉េចបាននុកដឹងថាផ្ញើមកហើយ

— ឮគេនិយាយព្រឹកមិញនេះពេញតែវាំង ។ បងទៅវិញហើយ ក្រែងព្រះករុណារក ។

# ៣

## អាចារ្យស្វានៅមាត់ជ្រូក

ជីស្វាតាំងខ្លួន ឬ អ្នកស្រុកខ្លះដែលមិនហៅថាព្រះអង្គគីម ហៅថាអាចារ្យស្វា ៗ លុះផ្ញើលិខិតទៅបារាំងនៅកេងដំរី ហើយ តាំងកៀសខ្លួនរកទៅជួបមនុស្សម្នាក់ដែលគេទុកចិត្ត ថា ជាអ្នកជួយក្នុងការកំចាត់យួន ។ ដើរចេញពីព្រាំងទៅទាំងយប់ ព្រោះមិនចង់ឲ្យអ្នកស្រុកដឹងថាទៅណាមកណា ។ អាចារ្យស្វាដើរកាត់វាលស្រែមិនឈប់ឈរសោះ ទៅដល់ក្ដិនចូលទៅមាត់ជ្រូក ខំសួររកឈ្មោះផ្ទះសួគ៌ាលោក ភៀវ ព្រោះអាចារ្យស្វា ធ្លាប់ឮគេនិយាយឈ្មោះនេះតាំងពីឧត្ដុង្គមកម្ល៉េះ ។ ទៅដល់ចូរជ្រុក (មាត់ជ្រូក) អាចារ្យស្វាបានជួបនឹងមនុស្សម្នាក់ឈ្មោះ ម៉ុម លីចបកាត់មុខអាចារ្យស្វា តម្រង់ទៅចុងភូមិ ។ អាចារ្យស្វាឃើញម៉ុមដូច្នោះ ក៏សួរថា :

— លោក! លោកមានស្គាល់ផ្ទះសួគ៌ាលោក ភៀវ ឬទេ?



— ផ្ទះសួគ៌ាលោក ភៀវ! បាទ នៅក្នុងនេះ ផ្ទះនរណាក៏ខ្ញុំស្គាល់ដែរ ។ ចុះលោកមកពីណា បានជាមកសួររកឈ្មោះសួគ៌ាលោក ភៀវ ដូច្នេះ ។

— ខ្ញុំហ៎! ខ្ញុំនេះហើយឈ្មោះអង្គ គីម ទើបតែមកពីស្រុកសៀមណា+

— សូមថ្វាយបង្គំព្រះអង្គ! សូមព្រះអង្គកុំចាប់កំហុសទូលបង្គំជាក្រល្ងង់ខ្លៅ ព្រោះទូលបង្គំមិនដែលឃើញព្រះអង្គសោះ ឮតែព្រះនាម ។

ម៉ុម នាំអាចារ្យស្វាទៅរកផ្ទះសួគ៌ាលោក ។ ទៅដល់ផ្ទះនោះហើយ ទើបម៉ុមឲ្យអាចារ្យស្វា (អង្គគីម) នៅខាងក្រៅរបងសិន គេដើរចូលទៅក្នុងរបងផ្ទះតែម្នាក់ឯង ។ ម៉ុមចូលទៅដល់ក្ដាម មានតែឆ្មាំផ្ទះទេ ដែលរត់មកទទួលមុនគេ ហើយឲ្យសញ្ញាទៅម្ចាស់ផ្ទះថាមានភ្ញៀវចូលមក ។ លោកស្រីសួគ៌ាលោក ភៀវ មើលតាមបង្អួចមក ក៏ឃើញម៉ុមចូលមកក្នុងរបងផ្ទះហើយ ទើបគាត់ប្រាប់ទៅស្វាមីវិញថា :

— ផុក ! តាម៉ុមបំភ្លេតនាំនរណាចូលមកក្នុងផ្ទះយើង គេនៅក្រោងណោះ ឯម៉ឺម្ន នេះនៅក្បែរជណ្ដើរ មើលទៅសួរវាមើល !

— សួគ៌ាលោក ភៀវ ចុះទៅដីហើយ ទទួលរាក់ទាក់និយាយនឹងម៉ឺម្ន ឲ្យដឹងហេតុផលសិនថា :

— ម៉េច ម៉ឺម្ន ឯងមកមានការអ្វី ?

— បាទ ! ខ្ញុំនាំព្រះអង្គ គីម មកជួបនឹងលោក ។ ព្រះអង្គថាមករកលោក មកតាមផ្លូវជួបខ្ញុំ ទើបពឹងខ្ញុំឲ្យជូនព្រះអង្គមក

— ព្រះអង្គ គីម !

— បាទ

— អ៊ីចុះនៅឯណា ?

— បាទនៅឯក្រៅរបង

— មក់ទៅជួបមើល

សួគ៌ាលោកបេះតែឆ្ងល់ថា ព្រះរាជបុត្រព្រះអង្គ អ៊ឹម ដែលព្រះនាមថា ព្រះអង្គ គីម នោះ គង់នៅឯស្រុកសៀមទេ ហើយ



កាលដែលអញឃើញម្ដងនៅឯឧត្តុង្គ ដូចជាមិនមែនហ្នឹងទេ ឬមួយអញលែងឃើញយូរទៅប្លែកដូច្នោះ ៗ ចិត្តនៅតែឆ្ងល់ តែដៃក៏លើកថ្វាយបង្គំអាចារ្យស្វាថា :

— សូមថ្វាយបង្គំ

អាចារ្យស្វាឃើញគេថ្វាយបង្គំ តាំងឡើងជាទ្វេថ្នាក់ទៀត ព្រោះថា បើសួគ៌ាលោកជឿថា អង្គ គីម ហើយ នរណាក៏ជឿដែរ ។ ឃើញសួគ៌ាលោកសំដែងអាការដូច្នោះ ក៏គិតថាបំណងអញបានសម្រេចហើយ ទើបតបទៅសួគ៌ាលោកភៀវ ថា

— ម៉េចលោកសុខសប្បាយឬទេ ?

— ទូលបង្គំសុខសប្បាយដូចធម្មតា

— ខ្ញុំខំកាត់មករកជួបនឹងលោក តាំងពីស្រុកសៀមមក ដើម្បីមកសួរលោក ហើយចង់ឲ្យលោកជួយខ្ញុំផង ៗ

— ទូលបង្គំជួយតាំងអស់ តែសូមយាងចូលទៅផ្ទះទូលបង្គំសិន

សួគ៌ាលោក ភៀវ នាំអង្គ គីម ក្លែងក្លាយចូលទៅក្នុងគេ-

ហង្គានរបស់ខ្លួន ហើយរៀបអាហារភោជនឲ្យបរិភោគដោយរាក់ទាក់ ព្រោះនឹកស្មានថា ព្រះអង្គ គឹម មែន ។ តែសួគ៌ាលោក ភៅ បែរគិតថា គេជាអញជាមនុស្សក្បត់នឹងស្តេច ហេតុអ្វីបានកូនស្តេចមករកអញដែរ ។ ការគិតរបស់សួគ៌ាលោកនេះ គ្មាននរណាជួយដោះស្រាយបញ្ហានេះទេ គ្រាន់តែគិតតែខ្លួនឯង ។ អាចារ្យស្វានៅមាត់ជ្រូកមានមនុស្សចុះចូលច្រើន ព្រោះនឹកស្មានថា ព្រះអង្គ គឹម ដូចជាសួគ៌ាលោកដែរ ។ ឯម៉ឹម វិញ តាំងពីបានជួបអាចារ្យស្វាថាអង្គ គឹមមក ចេះតែដើរអួតថា ខ្លួនជាអ្នកបំរើផ្ទាល់ព្រះអង្គ គឹម ហើយដើរទៅណាមកណាលីតែចប រហូតដល់ទៅអ្នកស្រុកឲ្យងារម្យ៉ាងទៀតថា សេនាជនចប ។

អាចារ្យស្វានៅមាត់ជ្រូកយូរៗទៅ ចង់ទៅបញ្ចុះបញ្ចូលរាស្ត្រនៅស្រុកត្រាំងឲ្យបានជឿស៊ប់ទៀត ទើបសួគ៌ាលោក ភៅ ថា :

— ខ្ញុំចង់ឲ្យរាស្ត្រនៅស្រុកត្រាំងទាំងអស់ជួយខ្ញុំ ក្នុង



ការដេញយួនឲ្យចេញផុតពីប្រទេសកម្ពុជា តើលោកមានយោបល់ដូចម្តេចខ្លះទេ ?

— បើសិនជាព្រះអង្គចង់ឲ្យរាស្ត្រនៅត្រាំងទាំងអស់ចូលក្នុងបក្សជាមួយ ត្រូវតែទៅទាក់ទងជាមួយពិស្ណុលោក ទេព សិន កាលបើពិស្ណុលោក ទេព ចូលហើយ សូមព្រះអង្គកុំព្រួយព្រះទ័យ

— មែនលោកមានប្រសាសន៍នេះត្រូវ ខ្ញុំនៅត្រាំងអស់ពេលច្រើនដែរ តែមិនបានទៅពឹងពាក់ជាមួយពិស្ណុលោក ទេព ទេ ។ អ៊ីចុះ យើងត្រូវធ្វើដូចម្តេចឲ្យពិស្ណុលោក ទេព ចូលមកក្នុងចលនារបស់យើង ?

— ស្រួលទេការនេះ ទូលបង្គំ មានមន្ត្រីម្នាក់ដែលអាចទៅនិយាយជាមួយពិស្ណុលោកទេពបាន គឺមន្ត្រីកូដាឯម

— កូដាឯម !

— ក្រាបទូលហ្នឹងហើយ

អាចារ្យស្វា បានទាក់ទងជាមួយមន្ត្រីកូដាឯមហើយ ក៏

ប្រើឲ្យទៅបញ្ចុះបញ្ចូលពិស្ណុលោកខេត្តនៅឯក្រាំង ។ មន្ត្រីកូជារឯម ទៅបញ្ចុះបញ្ចូលបានរាស្ត្រជាច្រើន ឲ្យចូលមកនៅជាមួយបក្សពួកអាចារ្យស្វា តែដល់មន្ត្រីកូជារឯមទៅជួបជាមួយពិស្ណុលោកខេត្ត ។ ក៏ឆ្លើយតបទៅមន្ត្រីកូជារឯមថា :

— អ្នកកុំមកបញ្ឆោតខ្ញុំ ខ្ញុំដឹងច្បាស់ណាស់ថា ព្រះអង្គ ភឹម ទ្រង់សុគតនៅឯបាងកកទៅហើយ ចុះមានអង្គភឹមឯណាទៀត អ្នកកុំដើរបញ្ឆោតរាស្ត្រដូច្នេះ កុំយកឈ្មោះគេមកលាបដូច្នេះ តែលោកនៅតែប្រព្រឹត្តដូច្នេះតទៅទៀត ខ្ញុំនិងចាត់ការតាមសេចក្ដីយល់របស់ខ្ញុំ ។

— មន្ត្រីកូជារឯម លែងនិយាយជាមួយពិស្ណុលោកខេត្ត ក៏គិតទៅបញ្ចុះបញ្ចូលរាស្ត្រតទៅទៀត ។ ពិស្ណុលោកខេត្ត ហាមមន្ត្រីកូជារឯមច្រើនដងនៅតែមិនស្ដាប់ ក៏ចាប់មន្ត្រីនេះដាក់ឃ្នាងយកទៅកាប់ចោលទៅ ។ ឯអាចារ្យស្វាដឹងដំណឹងថា ពិស្ណុលោកខេត្ត ចាប់បំរើរបស់ខ្លួនយកទៅប្រហារជីវិតហើយ ក៏លើកទ័ពតាម ជាមួយសេនាជួនបងម៉ុម ទ័ពអាចារ្យ



ស្វា លើកកាត់ព្រៃមកក្រាំង ស្រាប់តែជួបនឹង បាឡាត់ឈឹម និងសេនាទិត ដើរកាត់មុខទ័ព ដោយមិនដឹងថាទ័ពអាចារ្យស្វាលើកមក ។ កូនចៅអាចារ្យស្វាខឹងណាស់ ក៏ចាប់អ្នក-ទាំងពីរយកមកសួរថា :

— ឯងដឹងថាយើងជានរណាឬទេ បានជាហ៊ានដើរកាត់មុខទ័ពដូច្នេះ ?

— ប្របាទ ខ្ញុំបាទមិនដឹងលោកជានរណាទេ ហើយខ្ញុំបាទមិនដឹងថាលោកលើកទ័ពមកទីនេះសោះ បានជាខ្ញុំដើរមកទីនេះ ។ ខ្ញុំបាទត្រូវការទៅបុងភូមិ ដោយមានការ ដែលកងការចាត់ឲ្យទៅ ។ ខ្ញុំបាទមិនមែនជាអ្នកព្រហើនកោងកាចទេ សូមលោកអភ័យទោស ។

— ឯងហ៊ានដើរកាត់ទ័ពអញ ចំជាព្រហើនមែន ណែនាយទាហានយកអាទាំងពីរនាក់នេះទៅកាប់ចោលទៅចុះ ។

ដើម្បីធ្វើគ្រោងការរបស់ខ្លួនឲ្យបានសម្រេច អាចារ្យស្វាត្រូវតែកាន់ច្បាប់ឲ្យតឹងឲ្យរាស្ត្រខ្លាច ។

— សេនាអាចារ្យស្វាសម្លាប់បាឡាត់ឈឹមនិងសេនាឌិត ហើយ ក៏លើកទៅមុខទៀត ។ ឯកជពិស្ណុលោកឌេព ឮដំណឹងថាអាចារ្យស្វាលើកទ័ពមក ក៏រៀបទ័ពត្រៀមចាំបំរុងនិងតវ៉ៃ តែមានអ្នកស៊ើបយកការទៅប្រាប់ថា ៖

— លោក! មិនបានទេ តាមខ្ញុំបាទឃ្លាំមើលស៊ើបយកការណ៍ទៅ ឃើញទ័ពអាចារ្យស្វាបាញ់ ទៅចេញសុទ្ធតែទឹក យើងនៅតទល់មិនបានទេ សូមលោកលើកទ័ពគេចចេញសិនទៅ ។

ឮដូច្នេះ កាពិស្ណុលោកឌេព ពិស្ណុលោកវៀតក និងគាថាល្អួងឌ៩ នាំទ័ពថយទៅក្រោយខាងជើងសិន ។

អាចារ្យស្វា ពេលនោះ មានរាស្ត្រចុះចូលណាស់ព្រោះដឹងថា អាចារ្យស្វានេះជាអង្គធីមផង ជាអ្នកពូកែផង ជាអ្នកដេញយួនឈ្លានពានផង ជាអ្នកមិនចូលចិត្តនឹងបារាំងផង ។

# ៤

## នាំខស្នោរ

អាចារ្យស្វាទៅបង្ក្រាបបញ្ចូលអ្នកស្រុកក្រាំងបាន ហើយតាំងដើរប្រមូលស្បៀងទុកសំរាប់ទ័ព រាស្ត្រជាច្រើនចុះចូល ព្រោះឃើញថាអាចារ្យស្វាជាអ្នកស្រឡាញ់ជាតិ ហើយមានឥទ្ធិឫទ្ធិខ្លាំងពូកែខាងមន្តសិល្បវិជ្ជាការប្រកំពល ។ តែ... ទៅដែលចុះចូល ។ ពេលនោះ សូម្បីតែយួនកប៉ុះប៉ុបេខ្ទះដែរ ៗ

នៅល្ងាចមួយនោះ អាចារ្យស្វាដើរទៅរកមើលកិនភាគភូមិ ដើម្បីនឹងសង់បន្ទាយ ស្រាប់តែជួបមនុស្សចំឡែកម្នាក់មកសុំចុះចូលថា ៖

— សូមព្រះអង្គទទួលយកខ្លួនខ្ញុំឲ្យនៅបំរើព្រះអង្គផង ព្រោះព្រះអង្គធ្លាប់ហែតាមព្រះបិតាព្រះអង្គមកយូរហើយ រហូតដល់ព្រះអង្គសុគត

— ឯងឈ្មោះអ្វី ?

— ទូលបង្គំនាម ដួង

— មកពីណា ?

— មកពីស្រុកអូរធំ

— មានចេះអ្វីខ្លះ ?

— ចេះធម៌អាថ៌មន្តអាគមបន្តិចបន្តួច

— ខ្ញុំត្រេកអរណាស់ ដោយបានលោកមកជួយជាកំលាំងខ្ញុំដូច្នេះ តែសូមលោកកុំក្បត់នឹងខ្ញុំណា៎

— ទូលបង្គំមិនក្បត់ទេ

— ដូច្នេះ សូមលោកមកតាមខ្ញុំមក ខ្ញុំត្រូវការទៅជួបលោកតាញ៉ៅ នៅវត្តគោករមៀតបន្តិច ដើម្បីនឹងសាកសួរលោកឲ្យបានដឹងការស្រុកទេសខ្លះ ។

— អាចារ្យស្វានាំដួងទៅជិតដល់វត្តគោករមៀតហើយ មានឧបាសកម្នាក់ទៅទូលលោកថា

— ព្រះតេជព្រះគុណ ! អង្គឌួង មករកជួបព្រះគុណហ្ន៎



— នៅឯណា ?

— នៅក្រៅវត្តឯណោះទេ តែខ្ញុំករុណាឃើញដួងនាំមក

— ដួងណា ?

— ដួងចំកួតអីនោះណា !

— ដល់តែហៅត្រឹមតែដួង អាត្មាលែងស្គាល់ហើយ បើគេថាដួងចំកួតទើបនឹកឃើញ ។ អើបើគេមករកយើងឯងនៅកុំអាលទៅណា ទៅរកទឹកតែមកចាំទទួលភ្ញៀវសិន ។

ការសន្ទនាជាមួយឧបាសកមិនទាន់ចប់ផង ស្រាប់តែឃើញអាចារ្យស្វានិងដួងចំកួតមកដល់កុដិលោកដែរ ។ ព្រះអង្គបានទទួលអាចារ្យស្វា តាមភេទជាបព្វជិត ហើយក៏មានថេរដីកាថា :

— អាត្មាឮថាព្រះអង្គមកគង់នៅទីនេះ បានដេញទ័ពយួនឲ្យចេញពីដែនកម្ពុជាទៅ អាត្មាត្រេកអរណាស់ តែអាត្មាមិនដឹងជាបានពាក្យឯណាថ្លែងអំណរគុណចំពោះព្រះអង្គទេ មានតែស្លាបារីទឹកតែ ។

— ខ្ញុំព្រះករុណាត្រេកអរហើយ ៗ ខ្ញុំព្រះករុណាមកនេះ រវល់តែដេញពួកសត្រូវ គេមកថ្វាយបង្គំព្រះអង្គមិនបាន ទើបតែពេលនេះ គេទៀតឱកាសមកថ្វាយបង្គំព្រះគុណ ៗ ខ្ញុំព្រះករុណាមកនេះ មានគោលបំណងមួយទៀតគឺចង់ឲ្យព្រះគុណមេត្តាប្រោសទាយទស្សន៍បន្តិច

— អាត្មាមិនជាអ្នកចេះដឹងអីខាងហោរទេ សព្វថ្ងៃគ្រាន់តែជួយការពារដោះទុក្ខឧបាសក-សិកាចំណុះជើងវត្តតែប៉ុណ្ណោះទេ ៗ

— ករុណាល្អណាស់ ដោយព្រះអង្គមានព្រះទ័យដូច្នេះ បានមន្តអាគមជួយដោះទុក្ខក្រស្ត ៗ បំណែកខ្ញុំព្រះករុណាវិញ មកនេះចង់ដឹងថា តើខ្ញុំព្រះករុណាបានប្រកបដោយលក្ខណៈកសិដូចម្តេចទៀត នៅក្នុងកាលនាអនាគត ? តើមានទំនាយដូចម្តេចខ្លះទេ ?

— អាត្មាមិនមានមន្តអាគមពូកែទេ សព្វថ្ងៃគ្រាន់តែជួយទុក្ខធុរៈឧបាសក-សិកាចំណុះជើងវត្ត ដែលឈឺថ្កាត់បន្តិចបន្តួច



— ព្រះករុណាវិសេសណាស់ បានព្រះអង្គជួយស្រោចស្រង់ដូច្នេះ ៗ បំណែកខ្ញុំព្រះករុណាវិញមករកព្រះតេជព្រះគុណនេះ ចង់ដឹងថា តើខ្ញុំព្រះករុណានេះ ប្រកបដោយលក្ខណៈត្រូវតាមទំនាយក្បួនខ្លះទេ ?

លោកតាពៅ យកក្តារឈ្នួនមកគូសតែពីរបីអក្សរ ទើបមានថេរដីកាជាចំណោទថា :

"អង្កែបគីង្គក់ជាឯងចាំយាម
ព្រះសាសនាដល់ក្លាមមិនដឹងប៉ុនសក់ ៗ
ផ្គរលាន់ខែបុស្សរាក់ខុសនឹងក្បួន
មេម៉ាយធ្វើខ្លួនចង់បានប្តីទៀត
មានប្តីពីមុនស្លាប់ពោលចង់មៀត
ចង់បានប្តីទៀតគ្រាន់ចិញ្ចឹមកូនដើម(១)"

អាត្មាស្លាមិនយល់ពាក្យទាំងនេះថាដូចម្តេច ព្រោះថាលោកតាពៅពោលពាក្យទាំងនេះជាប្រស្នា ដូច្នេះហើយបានជាអា-

១ — ពាក្យនេះជាពុទ្ធដីការបស់លោកតា ពៅ ហៅអធិការ វត្តគោករមៀត ។

ចារ្យស្វាមិនយល់ន័យ ម៉្លោះហើយចេះតែគាត់ស្មានប្រហែលៗ ទៅ ។ គាត់ចាំបានថា „សាសនាដល់ភ្លាម„ នេះជាពាក្យ ដែលគាត់ថា „សាសនាដល់ហើយ" ត្រូវតែប្រញាប់មានអ្នក មានបុណ្យ ដូចបេះដល់ដូចសំដីលោកតាញៀមានពុទ្ធដីកាជាចំ- ណោទ គាត់ក៏គាត់ស្មានថា គាត់ហ្នឹងហើយដែលជាអ្នកមាន បុណ្យ ។ អាចារ្យស្វាលាលោកចេញមកហើយ នាំទ័ព ទៅបោះនៅឯព្រីងធំភ្លាម ។ ពេលនោះ មានអ្នកយកការណ៍ មកប្រាប់អាចារ្យស្វាថា:

– លោកទ័ពយួនមកច្រើនណាស់

– ទ័ពយួន ! ក្រែងវារត់ទៅស្រុកអស់ហើយ ?

– បាទ វាទៅមែន តែវាទៅនាំទ័ពមកថែមទៀត មក ច្រើនណាស់ ។

– ទ័ពយួនមកពេលនេះ មានចំនួនច្រើនណាស់ មក វាយកំចាត់ទ័ពអាចារ្យស្វាឲ្យថយពីកន្លែងនោះ ។ ទ័ពអាចារ្យ ស្វាធន់មិនបាននឹងទ័ពយួន ក៏នាំទ័ពទៅនៅព្រះបាទជាន់ជុំ ។



ហើយក៏ឲ្យរាស្ត្រប្រជាពលសេនា ធ្វើរាំងមួយអំពីដើមស្នោរ បានជារាស្ត្រហៅថារាំងស្នោរ ។ បោះទ័ពឲ្យនៅស្រួលបួល ហើយ ដើម្បីកុំឲ្យខ្ជិលយក្នុងការធ្វើបំបាំង អាចារ្យស្វា បាន ឲ្យពលសេនារៀបចំជប់លៀងដោយមានរាំច្រៀងផង ។ ពល សេនាខ្លះ ដើម្បីលើកទឹកចិត្តអាចារ្យស្វា នាំគ្នាច្រៀងថា:

កណ្ដៀង ១ ហើយដុះរៀងដើងភ្នំ
អ្នកអើយកុំយំ ម្ចាស់យើងបានថ្កើង (១)

. . . . . . . . . . . .

. . . . , . . . . . . .

ពលសេនាខ្លះក៏ច្រៀងរាំរែក ខ្លះក៏គ្រាន់ស៊ីផឹក តែអាចារ្យស្វា មិនភ្លេចទុកដាក់ឲ្យអ្នកនៅយាមល្បាត ក្រែងមានសត្រូវបន្ទំ ចូលមកឡើយ ។

---

១ – លោកសក់ខាត់ បានមានប្រសាសន៍ប្រាប់ចម្រៀងនេះថា នៅពេលដែល អាចារ្យស្វាលើកទ័ពកាត់ទៅបសែត ។

# ៥

## ឧកញ៉ាចក្រីកែប

នរណាមួយមិនដឹងថ្វីដែរ ឧកញ៉ាចក្រីកែប គ្រាន់តែឮឈ្មោះ ក៏គោរពចិត្តដែរ ។ ឧកញ៉ាចក្រីកែប ជាមនុស្សស្នេហារាជបល្ល័ង្ក មិនព្រមចេញទៅធ្វើជាបដិវត្តន៍ ប្រឆាំងនឹងបរទេស ដែលចូលមកនៅត្រួតត្រាប្រទេសកម្ពុជា លោកសុខចិត្តនៅចាំរក្សាការពារតែព្រះនរបតីជានិច្ច ។ ទោះបីមានអ្នកស្នេហាជាតិចេញទៅតតាំងធ្វើជាទ័ពបដិវត្តន៍ មិនព្រមឲ្យបារាំងចូលមកការពារប្រទេសកម្ពុជាក៏ដោយ លោកស៊ូនៅត្រាំការពារប្រទេស ការពាររាស្ត្រ តែក្នុងរាជធានី ។ លោកមានគូគនម្នាក់ទៀត ដែលមានសេចក្ដីស្នេហារាជបល្ល័ង្កដែរ អង់អាចក្លាហានមិនចាញ់លោកទេ គឺលោកឧកញ៉ាធម្មាប៊ុនអ៊ ។

ថ្ងៃមួយពេលរសៀល ឧកញ៉ាចក្រីកែប ចេញមកពីគាល់ព្រះនរបតីវិញ លោកមានទឹកមុខញញឹមប្រិមប្រិយ ហាក់



ដូចជាបានវត្ថុអ្វីមួយ ដ៏ជាទីគាប់ចិត្ត ។ លោកមិនទាន់ចូលទៅក្នុងផ្ទះភ្លាមទេ ព្រោះលោកសង្ឃឹមញញឹមក្នុងចិត្ត នូវរឿងអាថ៌កំបាំងអ្វីមួយ ទើបជិះសេះហួសទៅប្រាប់គូកនឧកញ៉ាធម្មាប៊ុនអ៊ ។ លោកចុះពីខ្នងសេះ ស្រាប់តែសុនខញីឈ្មោល ព្រួសឲ្យសញ្ញាគេហសាមីថាមានភ្ញៀវមក នៅពេលដែលលោកចងសេះជាប់នឹងដើមឈើក្បែរផ្លូវចេញចូល លោកគួរសមនឹងគេហបាលថា :

— អាឆ្កួត ! មើលសេះអញផង !

សុនខជាគេហបាល ក៏បក់កន្ទុយចូលមករកលោកជាមិត្ត នៃចៅហ្វាយរបស់ខ្លួន ហើយនាំគ្នាដេកនៅក្បែររបងផ្ទះ ។ ឯឧកញ៉ាធម្មាប៊ុនអ៊ ក៏ចុះមកទទួលមិត្តតាមសញ្ញានៃសុនខដែរ ទើបនាំឧកញ៉ាចក្រីកែប ឡើងទៅលើផ្ទះ

— ម៉េច ! មកពេលថ្មើរណេះ មានការអ្វីដែរ ?

— មុនខ្ញុំចូលទៅគាល់ព្រះនរបតី ខ្ញុំមកមើលលោកដែរ តែខ្ញុំឃើញផ្ទះលោកបិទទ្វារអស់ ខ្ញុំក៏ត្រឡប់ទៅគាល់ព្រះបរម

រាជវាំងតែម្នាក់ឯងទៅ

– ខ្ញុំរវល់ទៅគិតគូរកូនចៅឲ្យកូនបន្តិចព្រឹកមិញនេះ ។ អីចុះ ឥឡូវលោកត្រឡប់មកពីវាំងវិញហើយ ?

– បាទមកវិញហើយ

– ព្រះអង្គមានបញ្ជាឲ្យមកតាមខ្ញុំទឹង ឬ ?

– ព្រះអង្គបញ្ជាមែន តែខ្ញុំបានទាត់តែងអស់ហើយ ។ ស្អែកនេះ ពេលយាម ៣ យើងត្រូវចេញពីបន្ទាយឧត្តុង្គ ហើយ ទៅជួបចារបុរសនៅឯភ្នំពេញ ដែលខ្ញុំបានបញ្ជូនឲ្យទៅយកការជាមុន

–ព្រះអង្គមានព្រះបញ្ជាឲ្យយើងទៅបង្ក្រាបទ័ពតាក់ហែងយោធា ឬ ?

– អ៊ីចឹងមែនហើយ តែកុំមាត់ឲ្យនរណាដឹង សូម្បីតែកងទ័ពដែលខ្ញុំបានរៀបចំហើយស្រេច ក៏មិនដឹងជារៀបទៅណាដែរ ។

– បើអ៊ីចុះស្រួលហើយ ព្រោះអីខ្ញុំបានប្រុងការខ្លះៗ



មកហើយ ។

សេនាឯកទាំងពីរបែកគ្នាហើយ ប្រុងប្រៀបរៀបចំការ-គ្នាតែរៀងខ្លួន លុះយាម ៣ គេឮសូរសន្ធឹកជើងសេះចេញពីបន្ទាយឧត្តុង្គ ក្រោមពន្លឺតារាករយពាសពេញនភាល័យ ។ សេនាឯក នាំមុខទ័ពតាមផ្លូវមកជួបតែសត្វពក្លាក់ ហើរចេញពីមុខដំណើរ ឯទ័ពវិញ កុំពុងតែផ្ដោះផ្ដងគ្នាទៅវិញទៅមក ។ កងទ័ពទៅដល់ភ្នំពេញ ជួបជុំនឹងចារបុរសគ្រប់គ្នា ហើយ ទើបចារបុរសមកជូនពត៌មានមេទ័ពរបស់ខ្លួនថា :

– សូមគោរព ! ទ័ពតាក់ហែងយោធា ដឹងថាទ័ពព្រះរាជាលើកមកច្រើន វាមិនហ៊ានតទល់ ក៏លើកទ័ពគេចទៅតាំងនៅឯខ្សាច់ប៉ុសទៅវិញហើយ ។

– វាទៅយូរហើយឬ ?

– ប្រហែលមិនជាយូរប៉ុន្មានទេ !

– បើដូច្នោះ នាំគ្នាលើកទៅតាមភ្លាម ។

ឧកញ៉ាបក្រីកែវ និង ឧកញ៉ាធម្មាឫទ្ធិ មិនបង្អង់ឲ្យទ័ព

កំហែងយោធាកែវ គេចរត់រួចឡើយ ។ លោកបានចាត់ឲ្យសេនាដេញតាមព័ទ្ធស្ទាក់ ចុះទូកឆ្លងទៅត្រើយខាងកើត បំ-ណែកឯឧកញ៉ាធម្មាតេជោ បានដឹងរឿងនោះ ក៏លើកទ័ពពីត្រើយខាងកើតផ្ទប់ប្រសប់មកទៀត ។ រត់ទៅណាក៏មិនផុត ឧកញ៉ាមហារិទ្ធិវន្តជាញជ័យ ស្ទួរ ទឹងកំហែងយោធា បញ្ឈប់ទ័ពតទល់វិញភ្លាម តែទ្រាំទឹងកំលាំងទ័ពស្តួចមិនបាន ក៏បរា-ជ័យរត់បែកខ្ចាត់ខ្ចាយអស់ទៅ តែទ័ពឧកញ៉ាធម្មាតេជោនៅតែដេញតាមទៅទៀត មិនឲ្យទ័ពកំហែងយោធាកែវរត់ទៅណារួចឡើយ ។ មិនឆ្ងាយប៉ុន្មាន ទ័ពឧកញ៉ាធម្មាតេជោទាញស្នាបាញ់សម្លាប់កំហែងយោធាកែវ ហើយកាត់យកតែក្បាលមកជូនឧកញ៉ាចក្រីកែប ទីឯឧកញ៉ាធម្មាប្រឹក្សាថា:

— ព្រះតេជព្រះគុណ ! ក្បាលនេះ ជាក្បាលកំហែងយោធាកែវ ។ ទ័ពយើងដែលនៅក្រោមបញ្ជាការឧកញ៉ាធម្មាតេជោឆ្មើងបានដឹងថាលោកលើកទ័ពមកកាត់កងទ័ពបះបោរ ទើបយើងខ្ញុំលើកមកផ្ទប់ចាប់បានកំហែងយោធាកែវ តែ



ស្តាយណាស់ ដោយកូនចៅហានខ្លះខឹងពេក ក៏សម្លាប់ក្បែរទៅកាត់យកតែក្បាលមកជូនជាភស្តុតាង ។

— បើវាស្លាប់ទៅហើយ ជាការស្រួលដែរ ព្រោះកុំឲ្យខ្វល់ទឹងនៅរក្សា តែគង់ទ័ពយើងមានបានរបស់ប្រពន្ធកូនទីងកងទ័ពទាំងអស់របស់វាឲ្យមកជាពលរបស់ខ្លួន ?

ប្របាទកូនចៅហានពួកវា គ្រាន់តែឃើញចៅហ្វាយរបស់ខ្លួនស្លាប់ ក៏នាំគ្នាចុះចូលភ្លាម ព្រោះយល់ឃើញថាកងទ័ពយើងជាកងទ័ពល្អ តែមានខ្លះ រត់រួចដែរព្រោះវាបានប្រព្រឹត្តអំពើឃោរឃៅលើជនស្លូតត្រង់ពេក ។

— ពេលនោះ ឧកញ៉ាធម្មាប្រឹក្សាថ្លែងថា

— អាណារត់រួចឲ្យវារត់ទៅសិនចុះ គង់តែចាប់វាបានថ្ងៃណាមួយមិនខាន ។ តែពេលនេះ កុំចោលក្បាលអាកំហែង-យោធាធ្វើអី ឲ្យឧកញ៉ាពោកឡាយដែលជាបក្សពួករបស់វាទូលក្បាលកំហែងយោធាកែវ ដើរស្រែកអាក្រាស ៣ថ្ងៃនៅឯផ្សារទើបសមនឹងមុខវាជាអ្នកបង្កចលាចល ។

– លោកនឹកឃើញនេះល្អណាស់

ឧកញ៉ាហោកឡាយ ដែលចូលជាមួយបក្សពួកក្បត់នោះ ត្រូវទណ្ឌកម្មទូលក្បាលកំហែងយោធា នៅឯផ្សារឧត្តុង្គ ដើរស្រែកតាមក្រោស ពេញតែផ្សារ ។ មនុស្សម្នាឈរមើល ត្រៀបត្រាឯកេង ៗ រីញនាំគ្នាដើរត្រេសតាមក្រោយ ព្រោះចង់មើលមុខមនុស្សបង្កចលាចល ។

ក្រោយនោះ មិនយូរប៉ុន្មាន ឧកញ៉ាវិទូរគ្គជាញជ័យ ស្នូរ កៅក្រហាយទីងទ័ពបក្រៃកែប ឧកញ៉ាធម្មាប៉ុក ឧកញ៉ាធម្មា ឆ្មាំខ ដែលលើកទៅសម្លាប់កំហែងយោធា កែងទ ហើយ យកក្បាលឲ្យឧកញ៉ាហោក ឡាយ ដើរស្រែកតាមក្រោស ផ្លូវរបាះទើបនាំគ្នាប្រមូលទ័ពបានជាច្រើន លើកទៅបំរុងនឹងចូលទៅកំទេចកងទ័ពឧកញ៉ាធម្មា ប៉ុក តែបែរទៅជាបកជ័យ នឹងទ័ពល្អនទៅទៀត មិនតែប៉ុណ្ណោះ ត្រូវកងទ័ពស្នេហាកជ បណ្ដាច់បានខ្លួនឧកញ៉ាមហាវិទូរគ្គជាញជ័យ ស្នូរ ផងៗគង់ ទ័ពឧកញ៉ាធម្មា ប៉ុក យកឧកញ៉ាមហាវិទូរគ្គជាញជ័យ ស្នូរ



ទៅដាក់ឃុំឃាំងទុកនៅក្នុងគ្រុងមួយ ដោយឲ្យកពីកងទ័ព ឈ្លើយផងដែរទៀត ។

នៅវេលាយប់នោះ ផ្គរមេឃម៉ោរខ្លាំងនឹក ភ្លៀងធ្លាក់ ដូចគេចាក់ហែកមេឃ អ្នកយាមគ្រុងឃុំឃាំងមនុស្សទោស គេចូលទៅជ្រកក្នុងជំរំ ឯឧកញ៉ាមហាវិទូរគ្គជាញជ័យ ស្នូរ ឃើញឱកាសស្ងាត់ ក៏ហែកគ្រុងលួចរត់ចេញពីគ្រុង ទៅជួបនឹងបក្សពួករបស់ខ្លួន ៗ បក្សពួកបង្កចលាចលឃើញចៅហ្វាយរបស់ខ្លួនរត់រួចមកបាន ត្រេកអរណាស់ ព្រោះអស់សង្ឃឹមទៅហើយ ទើបមានអ្នកខ្លះសួរចង់ដឹងឥទ្ធិឫទ្ធិដែលបានរួចចេញពីគ្រុងថា :

– មេចបានជាលោករត់រួច ?

– យប់មិញ ពេលកំពុងតែភ្លៀងធំ គ្មាននរណានៅយាម ខ្ញុំលួចកាច់ហែកគ្រុងហើយលបចេញមកយ៉ាងស្រួល ។

– យើងខ្ញុំនៅឯណោះមិនព្រងើយដែរ បានចាត់ឲ្យទ័ពខ្លះ តាមទៅស៊ើបសួរមើលកន្លែងដែលគេឃុំឃាំងលោក ចាត់ខ្លះ

ឲ្យទៅកេណ្ឌទ័ពមកបន្ថែម

— កុំគិត ឥឡូវនេះ ខ្ញុំត្រឡប់មក បាទពត៌មានខ្លះថា លោកឧកញ៉ាកដេជៈ **ហាយ** ឧកញ៉ាជំរុំស្នួស សួងគីខ ត្រឡប់មកដែរ ហើយទៅកេណ្ឌទ័ពមកទៀត ហើយដល់បានជួបជុំគ្នា នឹងធ្វើនទៅត្រើយឯណោះ ដើម្បីទៅសុំចុះចូលជាមួយបារាំង ហើយបោកបារាំងយកកាំភ្លើងឲ្យបានច្រើន ។

— ចាំងគស់គ្នា ក៏ទទួលយល់ព្រមតាមការបាត់ការភ្នាម ។ ។ លុះប្រមូលបានរួចហើយរៀបតែចេញដំណើរទៅ គ្រាប់តែទាហានជំនិតរបស់ឧកញ៉ាមហាទិទ្ធវង្សជាញជ័យ ពីរនាក់ដឹងការសម្ងាត់ក្នុមួយ ស្ទុះចូលទៅចាប់ឧកញ៉ាជំរុំស្នួស បង្ហាញសេក ហើយយកមកជូនមេទ័ពរបស់ខ្លួន ។ កូនទ័ពទាំងអស់ទៅជាស្រឡាំងកាំងកល់គ្នា តែមិនហ៊ានស្ទូរនាំគ្នា ព្រោះខ្លាចអំណាចមេទ័ព ។ ឧកញ៉ាមហាទិទ្ធវង្សជា-ញជ័យ មិនបង្អង់ឲ្យយូរដំណើរ ទើបបញ្ជាឲ្យកូនទ័ពសម្លាប់ឧកញ៉ាជំរុំស្នួសពេលទៅ ហើយទើបនាំទ័ពទាំងអស់ទៅ



ចំនុំបារាំងនៅក្រចេះ តាមគោលបំណងដែលគ្រោងទុកមក ។ មេទ័ពបារាំងដដែល ពួកនេះសុទ្ធតែជាពួកក្បត់ទឹងព្រះរាជានៃប្រទេសកម្ពុជា ក៏បង្គាប់ឲ្យទាហានខាងក្រុមសម្ងាត់ថា:

— លោកកាប៉ូរ៉ាល់ ឯងនាំពួកវាទៅកន្លែងកេសដ្ឋ:បង្អត់ឲ្យស្រវឹង លុះវាស្រវឹងហើយ នាំវាទៅណា

— គោរព !

— នាំវាទៅចុះកប៉ាល់ ដែលនៅត្រៀមចាំជាស្រេច ហើយកុំឲ្យវាដឹងថានាំយកទៅណា ណា ។ បើវាសួរដេញដោលឯងប្រាប់វាថា ទៅយកកាំភ្លើងណា

— បាទ !

កាប៉ូរ៉ាល់ចាំងនោះ នាំទ័ពក្បត់ទាំងអស់ចុះក្នុងកប៉ាល់មួយ ។ អ្នកទាំងអស់គ្នាបេះតែសង្ស័យដែរ តែដល់ឮថាទៅយកកាំភ្លើង ក៏លែងឆ្ងល់ទៅ ព្រោះគោលបំណងរបស់ពួកនេះ គិតតែរកមធ្យោបាយឲ្យរួចពីការកាប់សម្លាប់ ដល់នាវាទៅបកនៅកណ្ដាលកោះមួយ នៅកណ្ដាលសមុទ្រទើបជីង

ខ្លួនខ្លះ ៗ ។

ក្រោយដែលកងទ័ពឧកញ៉ាមហាវិទ្ធិរង្គជាញជ័យ ទទួលនូវបរាជ័យលែងត្រឡប់មករកផ្ទះសម្បែងវិញ ព្រះបាទសម្តេចព្រះនរោត្តមទ្រង់ប្រោសតែងតាំងឧកញ៉ាធម្មា ប៉ុក ឡើងយសសក្តិជាសម្តេចចៅពញ៉ា ។

– ឯកងទ័ពអាចារ្យស្វានៅកំពុងតែប្រព្រឹត្តសកម្មភាពកាន់តែខ្លាំងនៅឯត្រាំង ទើបរាជការចាត់ឲ្យឧកញ៉ាចក្រី កែបទៅគ្រួតត្រានៅទីនោះ(១) ។ ឧកញ៉ាចក្រី កែបបានលើកទ័ពដេញតាមទ័ពអាចារ្យស្វា ដោយគ្មានកោតញញើតឡើយ សូម្បីដឹងថា អាចារ្យស្វា នេះគួរតែត្រង់ឲ្យក្លាយទៅជាពល ក៏នៅតែចក្រី កែប មិនរាថយក្រោយដែរ ព្រោះលោកក៏មានមន្តអាគមគាថាយ័ន្តការពារស៊ុបដែរ ។ តែទោះបីជាខ្លាំងពូកែយ៉ាងណា ក៏រត់មិនរួចនឹងរាស្ត្រ ដែលអាចារ្យស្វាបានអប់រំមកជាច្រើនខែដែរ ។ រាស្ត្រនៅតំបន់នោះស្ទើរតែទាំងអស់ ចុះចូល

១ – ព្រះរាជពង្សាវតារសរសេរដោយពុទ្ធសាសនបណ្ឌិត្យទំព័រ ៩១៩ ។



នឹងអាចារ្យស្វា ម្ល៉ោះហើយឧកញ៉ាចក្រី កែប ត្រូវតែបរាជ័យនឹងទ័ពអាចារ្យស្វា ។

ពេលច្បាំង ទ័ពអាចារ្យស្វាធ្វើហាក់ដូចជាចាញ់កលរបស់ទ័ពឧកញ៉ាចក្រី តែពេលយប់ទ័ពអាចារ្យស្វាលបបណ្តាក់គ្នា ចូលទៅក្នុងបន្ទាយទ័ពឧកញ៉ាចក្រី កែប បានហើយក៏សម្លាប់ឧកញ៉ាចក្រី កែប បាននៅក្នុងខេត្តត្រាំងទៅ ។

# ៦

## ឧកញ៉ាក្រឡាហោមថាំង

ការធ្វើឃាតកម្មឧកញ៉ាចក្រីក្អែប ធ្វើឲ្យប្រជារាស្ត្រច្រួលច្របល់ស្ទើរតែសព្វកន្លែង ៗ ចំណែកទ័ពអាចារ្យស្វាបានសម្លាប់ចក្រីក្អែបហើយគាត់តែក្លាហានឡើង ៗ ៗ ឯអាចារ្យស្វាទឹកដល់ពាក្យ លោកតាពៅថា «សាសនាដល់ហើយ» លែងគិតពីសេចក្ដីវេទនា លែងគិតហើយសេចក្ដីស្លាប់ ហើយឲ្យតែប្រទះមុខ នរណាពាំងផ្លូវ មុខតែទ័ពអាចារ្យស្វាកាប់សិនដែរ មិនដឹងជាទ័ពណាឡើយ ៗ ការបាត់បង់ជីវិតឧកញ៉ាចក្រីក្អែបនេះ ឮទៅដល់កុម្ម៉ាំជង់ ឧញាជំឡាត្រែ ទើបឧញាជំឡាត្រែ តាក់ឲ្យមន្ត្រីពជការចូលទៅកាន់ព្រះបរមរាជវាំងជំណាក់ ដើម្បីចាំស្ដាប់ព្រះរាជឱង្ការ នៃសម្ដេចព្រះនរបតីពេលដែលព្រះអង្គទ្រង់ក្រសាលនៅជំណាក់ភូមិគោកពន្លឺខេត្តកំពត ។



ព្រះនរបតីទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់មានព្រះទ័យសោកសៅព្រះអង្គប្រាណព្រួយព្រះរាជហឫទ័យស្ទើរស្រក់ព្រះលោហិត ព្រះអង្គទ្រង់កំពុងតែក្រសាលសំរាកព្រះកាយពល ដល់ព្រះអង្គទ្រង់ជ្រាបនូវពត៌មាននេះ ទើបព្រះអង្គស្ដេចយាងនិវត្តចូលទៅព្រះរាជជំណាក់នៅឧត្តុង្គមានជ័យវិញ ព្រះអង្គយាងចូលទៅដល់ព្រះរាជជំណាក់ហើយ នៅវេលាយប់នោះ ព្រះអង្គទ្រង់មានព្រះតម្រិះ តែមួយព្រះអង្គឯងនៅក្នុងព្រះជំណាក់ ព្រះអង្គមិនឲ្យនរណាចូលគាល់ព្រះអង្គឡើយ ព្រះអង្គទ្រង់មានព្រះចិន្តាថា «អាចារ្យស្វា ! មិនគួរបែរទៅជាមនុស្សក្បត់ជាតិបាននោះ នេះមកតែពីលោកបានជាបែរទៅជាក្បត់ដូច្នេះ» ៗ ព្រះអង្គទ្រង់ព្រះចិន្តាដូច្នេះ ទើបទ្រង់បញ្ជាឲ្យអាមាត្យទៅតាមនាម៉ឺនសព្វមុខមន្ត្រីខ្លះឲ្យចូលមកគាល់ ៗ ពេលនោះឧកញ៉ាក្រឡាហោម ថាំង ទើបតែវិលមកពីបន្ទាយនៅភ្នំពេញជាមួយឧកញ៉ាវង្សាអគ្គរាជ នុំ ឧកញ៉ាអជូនស្វ៊ី ឧកញ៉ាពុល ម៉ែន ចូលទៅក្រាបបង្គំគាល់ ៗ នាម៉ឺនបាននោ-

ពេព្រះអង្គរួចហើយ ទើបព្រះនរបតី មានព្រះបន្ទូល

— លោក ! ស្រុកយើងពេលនេះ កំពុងតែមានចលា-ចលពាសពេញនៃនគរ ព្រោះគេយល់ឃើញថា ស្រុកខ្មែរនៅក្រោមការត្រួតត្រាបរទេស គេមិនចង់ឲ្យបរទេសត្រួតទេ ៗ មានអ្នកខ្លះបានចូលទៅសុំខ្ញុំ ខ្លះទៀតទៅដោយចិត្តឯង ដើម្បីចេញមុខប្រឆាំងនឹងបរទេស តែមិនដូច្នោះបែរទៅជាសង្កត់សង្កិនខ្មែរគ្នាឯង ៗ អ្នកខ្លះបានទៅដេញទ័ពយួនឲ្យចេញពីស្រុកខ្មែរ តែក្រោយមកឡើងដោរ លែងគិតរាស្ត្រជាតិដូចគ្នា ព្រោះដោរនឹងបុណ្យសក្តិ ហើយទៅធ្វើបាបរាស្ត្រដែលស្លូតត្រង់ ៗ ពេលឥឡូវនេះ អាចារ្យស្វាដែលស្នេហាជាតិទៅដេញមុននោះ បានសម្លាប់ឧកញ៉ាបក្រីអៃឫទៅហើយ ឃើញថា អាចារ្យស្វាតែតុកយូរទៅមុខតែនាំឲ្យកើតចលាចលរឹតតែខ្លាំងឡើង ៗ ដូច្នេះខ្ញុំចាត់ឲ្យឧកញ៉ាក្រឡាហោមឡាំខ១ ឧកញ៉ាវង្សាអគ្គរាជ អ្នក១ ឧកញ៉ាអរជូន ស្ទើ១ ឲ្យលើកទ័ពដើរគោកទៅព័ទ្ធចាប់ទ័ពអាចារ្យស្វាឲ្យបាន ៗ ចំណែកលោក



វិបុលរាជ ម៉ែនឲ្យលើកទ័ពដើរទឹកទៅចាំស្ទាក់កុំឲ្យរត់រួច ៗ តែលោកប្រយ័ត្នឲ្យមែនទែន កុំឲ្យមានការគ្រោះថ្នាក់ណា ៗ

ឧកញ៉ាក្រឡាហោម ឡាំខ បានទទួលព្រះរាជបញ្ជាទៅបំពេញបេសកកម្ម យល់ស្របតាមព្រះរាជបញ្ជាជំនួសវីរបុរសទាំងនោះយ៉ាងសប្បាយ តែមុននឹងក្រាបថ្វាយបង្គំលាព្រះនរ-បតី ឧកញ៉ាក្រឡាហោម ឡាំខ បានទូលព្រះរាជាថា :

— សូមព្រះរាជតម្កល់លើត្បូង ! ទូលបង្គំបានចាត់ការនេះខ្លះ ១ ទៅហើយ ចាំតែបារបុរសក្រុមទី ២ មក ទូលព្រះបង្គំនឹងចាត់ចែងមិនបង្អង់ឡើយ

— ខ្ញុំបានជ្រាបមុនដែរហើយ តែសូមលោកចាត់ការនេះឲ្យប្រញាប់បន្តិច

ទាំងអស់គ្នា ក៏អង្គុយដោយគុណ្ហភាពហើយក្រាបថ្វាយបង្គំព្រះនរបតី ទៅបំពេញបេសកកម្មតាមមុខក្រសួងរបស់ខ្លួន ៗ គង់ទ័ពព្រះរាជាបានចេញដំណើរទៅតាមដើរទឹក គោក តាមបញ្ជានៃមេក្រុម មេកងរបស់ខ្លួន ឆ្ពោះទៅរកស្រុកជើងកញ្ចុំ ៗ

ចំណែកទំពអាចារ្យស្វា ដែលកំពុងតែសប្បាយរីករាយនឹងការដេញទំពឈ្លានពានស្រុក ឯអាចារ្យស្វាសប្បាយនឹងបុណ្យស័ក្តិដែល រាស្ត្រនាំគ្នាចុះចូល ។

ថ្ងៃនេះ អាកាសធាតុក្តៅថែបជាធម្មតា នៅតាមភូមិនិគមជនបទខ្លះ ទឹកត្រពាំងរីងហួត ទំពអាចារ្យស្វាមានសេចក្តីលំបាកខ្លះនឹងទឹក ។ ស្វាសិទ្ធមិនបានទៅរួមជីកអណ្តូងជាមួយគេទេ ព្រោះមានធុរៈទៅជួបសង្សារដែលបំរុងនឹងរៀបការក្នុងពេលខាងមុខនេះ ។ ស្វាសិទ្ធចេញទៅបានជួបនឹងឪពុកមាលីចបទៅជីកអណ្តូងទឹក តែលោជាជួបនឹងក្មួយថ្លៃ ទើបនិយាយនឹងស្វាសិទ្ធថា

— ក្មួយ ! ក្មួយប្រយ័ត្នមែនទែន នារីទាំង ៤ នាក់ ដែលមកស្ម័គ្រចូលជាសេនានោះ បើតាមយោបល់ពូថា នាំឲ្យតែវិនាសក្មួយទេ ។ ក្មួយប្រយ័ត្នមែនទែន នាងរឿនមិនស្រួលទេ ព្រោះខ្ញុំលបមើលឃើញខ្លះ ៗ ដូចជាចេះតែទៅខេស្និទ្ធស្នាលជាមួយលោកមេទ័ព !



— ខ្ញុំដឹងខ្លះ ៗ ដែរ សូមកុំព្រួយ ! ពូមកណោះខ្ញុំរៀបរឿងនេះ តែសូមកុំមានប្រសាសន៍ប្រាប់នរណាដឹងឲ្យសោះ

— មិនអីទេ

— មេទ័ពយើងនេះ មិនមែនគន្ធ ត្រឹម្រះទេ

— អីចុះនរណាទៅវិញ ?

— នេះគេហៅទៅឧទ្ទិដ្ឋជាអាចារ្យស្វា ៗ ជាបាវរបស់គេ

— តែឥឡូវខ្លាំងពូកែដូចេះ នរណាធ្វើអីកើត

— មិនអីទេពូ ខ្ញុំបានចាត់ចែងនាងរឿនឲ្យទៅបំរើផ្ទាល់លោកមេទ័ពៈទៅហើយ ។ ឥឡូវពូទៅចុះ ខ្ញុំទៅក្ដិជនមួយកែ្ត តែសូមពូនៅឲ្យស្ងៀមណាំ

— មិនអីទេ

ស្វាសិទ្ធថ្មៀតឱកាសនេះ ទៅជួបនឹងតាបុរសរបស់ក្រឡាហោមបាំងដែលលបចូលមកព្រាំងតាមសេចក្តីពន្យល់របស់នាងរឿន ។ ស្វាសិទ្ធមកដល់ព្រាំង នរណាម្នាក់មិនស្រឡាញ់ស្វាសិទ្ធ ឃើញស្វាសិទ្ធមកដូះបុះមាន

សេចក្ដីរីករាយណាស់ ចង់តែនិយាយការសម្ងាត់ប្រាប់សួនសិទ្ធទេ តែមិនដឹងជាសួនសិទ្ធ មានចិត្តថ្លុកដូចម្ដេច ៗ សួនសិទ្ធ បានទៅស្នាក់រកជួបតាប៉ុស ហើយនិយាយដឹងគិតនឹកគាត់គ្នាហើយទើបត្រឡប់ទៅក្នុំដិនវិញ ៗ

នាង ឡី កំពុងតែកណ្ដៀតក្អមទៅរណ្ដៅទឹកក្បែរស្លូវជើងសេះក៏នឹកស្មានថា ជាជើងសេះតាប៉ុសយួន ក៏ផែបទៅគុម្ពចេកសិន លុះឃើញមនុស្សប្រាសក៏ចេញមកជួប

— បងឯងញ៉ើញមកធ្វើអ្វីហ្នឹង ?

— មករកអូនឯងណា

— មក ! យកសេះទៅលាក់ទៅ

— ពុកអញ្ជើញទៅណា ?

— ទៅវត្តអម្បាញ់មិញហ្នឹង

— ធ្វើម៉េចទៅតាមគាត់មកបាន

— បងនៅទីនេះហើយ ខ្ញុំទៅតាមគាត់

នាងឡី ចេញទៅតាមបិតានៅឯវត្តតាមផ្លូវក្នុងភូមិ ព្រោះ



កាត់តាមជល់ តែមិនដឹងជាមានមនុស្សម្នាក់មកតាមរកសួនសិទ្ធទេ ៗ នាងធឿនជិះសេះបណ្ដើរ រកមើលផ្ទះតាមសញ្ញា មកដល់មុខផ្ទះនាង ឡី ទើបដើរចូលទៅ

— ណែ ធឿន !

នាងធឿនភ្ញាក់នឹងមនុស្សដែលហៅចំឈ្មោះនាង

— ម៉េចមានការអី ?

— មានការវឹកវរយ៉ាំងខ្លាំងណាស់! សេនាជួចចប់ចប ដឹងផែនការយើងហើយ

— មិនអីទេ រួចម៉េចទៅទៀត

— ខ្ញុំស្មានថា សេនាជួចចប់រកចាប់កំហុសពួកយើង

— ខ្ញុំព្រួយណាស់

កំពុងតែនិយាយឆ្លើយឆ្លងគ្នា នៅក្បែរគុម្ពចេក នាង ឡី ក៏ត្រឡប់មកវិញដែរ ឃើញនាង ធឿន អង្គុយតែបសួន សិទ្ធ នឹកស្មានថា ជាសង្សារដែរ ក៏ចង្អុលមុខសួន សិទ្ធភ្លាម

— យើ ! ស្មានថាមករកខ្ញុំ មិនដឹងជាមកប្រើខ្ញុំទៅហៅ

ឪពុកខ្ញុំមកសុំផ្តាច់ពីខ្ញុំ ទៅចេញទៅ ! មិនបាច់ចាំជួបគាត់ទេ !

ស្នងសិទ្ធ, នាងរឿនស្រឡាំងកាំង រកនិយាយដូចម្តេចក៏មិនកើត ព្រោះមិនបានដឹងរឿង តែនាងឡឺនិយាយផុតទើបដឹងថា នាងស្មានខុស ទើបនាងរឿនតាមទៅសុំទោសនាងឡឺ តែនាងឡឺមិនបានមើលមុខនាងរឿនទេ ។ ឃើញអាកប្បកិរិយារបស់នាងឡឺដូច្នោះ នាងរឿនក៏ជិះសេះទៅជំរំវិញ ទៅ ឯនាងឡឺក៏ទៅយកសេះមកឲ្យស្នងសិទ្ធ

— ទៅចេញទៅ !

— អូន ! កុំប្រឡំ ! មិនមែនសង្សារប្រុសកំណាន់របស់បងទេ !

— ទុកជាយ៉ាងណា ក៏លែងរាប់វាជាស្មោះត្រង់នឹងខ្ញុំដែរ សូមតែចេញទៅ !

នាងឡឺឈប់និយាយ ស្រាប់តែឪពុកមកដល់ដែរ គាត់ឮជជែកគ្នាដែរ តែគាត់មិនបានទៅលួងលោមកូនគាត់ទេ គាត់បែរជាទៅនិយាយជាមួយស្នងសិទ្ធថា:



— កូន នៅឯកំពង់ស្ពានឯណោះ កំពុងតែកើតកែរសម្បើមណាស់ កូនប្រញាប់ទៅមើលទៅ ក្រែងមានគ្រោះថ្នាក់ដល់យុវតីដែលនៅឯកំពង់ស្ពានឯណោះ ។

ស្នងសិទ្ធចេញទៅ ទើបឪពុកនាងឡឺទៅរកកូនគាត់ដែលអង្គុយយំតែម្នាក់ឯង

— កូន ! កូនកុំស្មានថា នាងរឿនដែលមកតាមប្តីកូននោះ ជាគេស្រីខូចនឹងប្តីកូន មិនមែនទេ គេជានារីមួយរូបដែលគួរគោរព

— គោរពដូចម្តេច បើខ្ញុំឃើញមកនិយាយជាមួយបងសិទ្ធដូចជាស្និទ្ធស្នាលណាស់

— កូនកុំស្មានដូច្នេះ វាមិនត្រូវទេ កូនចាំតែមើលបន្តិចទៀត ទៅមើល តើវាទៅជាយ៉ាងម៉េចទៅវិញរឿងនេះ

នាងឡឺ មិនហ៊ានតបទៅនឹងឪពុកទៀត ក៏នៅតែស្ងៀម ឯស្នងសិទ្ធទៅដល់ជិតកំពង់ស្ពាន ក៏បានជួបនឹងនាងរឿន

— លោក ! ពួកយើង ដែលចូលទៅប្រលោមលួង

លោមអាចារ្យស្វាបានសំរេចអស់ហើយ ឥឡូវវត្ថុដែលជាទីពឹងនៃអាយុជីវិតរបស់អាចារ្យស្វា ត្រូវពួកយើងលួចយកបាន ហើយយកទៅបោះចោលក្នុងបង្គន់អស់ទៅហើយ តែនឹកគួរឲ្យព្រួយបារម្ភជាខ្លាំង ព្រោះអាចារ្យស្វាពេលដែលបាត់វត្ថុសក្ដិសិទ្ធនោះទៅ ក៏សង្ស័យទៅលើពួកខ្ញុំ តែពួកខ្ញុំបាននាំគ្នាគេចទៅបាត់អស់ ។

— ចុះអាចារ្យស្វាទៅណាទៅ ?

— ទៅតាមពួកខ្ញុំទៅហើយ ឯខ្ញុំចេញទៅមិនទាន់បាន គ្រាន់តែដឹងដំណឹងនេះភ្លាម ខ្ញុំគេចមកជួបលោកវិញ ។ ឯពួកខ្ញុំ ៤ នាក់គាត់ទៅតាមច្រាំងទៅរកជួបជាមួយលោកក្រឡាហោមប៉ាង ។

នាង ទៀន និយាយបានតែប៉ុណ្ណោះ គិតគេចចេញពីស្ពង់សិទ្ធតែស្ពង់សិទ្ធឃាត់ទុកសិន មិនឲ្យនាងចេញទៅក្រែងមានគ្រោះថ្នាក់ ។ ចំណែកឯអាចារ្យស្វាទៅតាមនារីមិនទាន់ មិនដឹងជាទៅណា ក៏តាំងតែដើរសួររកស្ត្រីនៅច្រាំង តែ



កស្ត្រីមិនហ៊ានប្រាប់ដែរ ព្រោះខ្លាចរាជការ ។ កស្ត្រីមានសេចក្ដីវេទនាលំបាកស្ទើរតែអត់ទ្រាំមិនបាន ណាខ្លាចអាចារ្យស្វា ណាមួយខ្លាចរាជការ ។ អាចារ្យស្វាលែងគិតឃើញអ្វីក្រៅពីតណ្ហា ម៉្លោះហើយចេះតែស្វែងរក នារីដែលលួចយកវត្ថុសក្ដិសិទ្ធនោះ ។

ចារនារីទៅដល់ជំរុំកងទ័ពក្រឡាហោមប៉ាងវិញ រាយការណ៍ពីបេសកកម្មរបស់ខ្លួនហើយ មួយថ្ងៃបន្ទាប់មក ទ័ពក្រឡាហោមប៉ាង ដែលរៀបប្រុងប្រៀបទុកស្រេច នាំគ្នាចេញតាមជើងទឹក គោក ឆ្ពោះទៅស្រុកជើងកញ្ចុំ ។ ឯទ័ពអាចារ្យស្វា ដែលកំពុងតែសប្បាយនឹងបុណ្យសក្តិ កំពុងតែសប្បាយនឹងស្ត្រីកោតខ្លាច គ្រាន់តែឮដំណឹងទ័ពព្រះរាជា ដែលមានក្រឡាហោមប៉ាងជាមេ ក៏នាំគ្នារត់ខ្ចាត់ខ្ចាយទៅឯកំពង់ស្នោរវិញសិន ។

ទ័ពក្រឡាហោមប៉ាងលើកដល់ច្រាំង មិនឃើញទ័ពអាចារ្យស្វា ក៏ចាត់ឲ្យទាហានខ្លះដេញតាមទ័ពអាចារ្យស្វា តែ

ទ័ពអាចារ្យស្វាទៅដល់ទាំងស្មោរ ក៏នាំទ័ពទៅឯមាត់ជ្រូកវិញៗ ឯទ័ពក្រឡាហោមប៉ាំងដេញតាមទ័ពអាចារ្យស្វាមិនទាន់ ក៏វិលត្រឡប់មកក្រាំងវិញ ទើបក្រឡាហោមប៉ាំងបញ្ជាទៀតថា

— លោក! ពេលនេះ បើទ័ពអាចារ្យស្វាទៅមាត់ជ្រូកហើយ វាមុខតែតាំងបន្ទាយនៅឯណោះទៀតហើយ ។ ឥឡូវបើសិនជាយើងលើកទ័ពទៅ វាចេះតែគេចរត់ ដូច្នេះខ្ញុំចាត់ឲ្យរាជអន្សោ សោម និងពិកក្ដិ អ៊ី នាំទ័ពខ្លះទៅតាមមើលកុំឲ្យទ័ពអាចារ្យស្វាចូលមកទាក់ទងនឹងរាស្ត្រទៀតបាន ហើយមិនយូរទេតែវាអស់ស្បៀងអាហារ វាមុខតែចូលមករំលុយស្បៀងអាហារទៀតហើយ ។

— សូមទទួលតាមបញ្ជាដោយគោរព!

# ៧

## ចលាចលនៅទាំងស្មោរ

ទទួលបញ្ជារួចហើយ រាជអន្សោសោម និងពិកក្ដីអី នាំទ័ពខ្លះចេញដេញតាមទ័ពអាចារ្យស្វា ហើយឧកញ៉ាក្រឡាហោមប៉ាំង ក៏នាំទ័ពចូលទៅឧដុង្គវិញ ដើម្បីយកពត៌មានទៅថ្វាយព្រះនរបតី ។ ទៅដល់មាត់ជ្រូករកកងទ័ពអាចារ្យស្វាមិនជួប ក៏ត្រឡប់មកក្រាំងវិញមិនបានចូលទៅជំរាបពត៌មានចំពោះមេបញ្ជាការរបស់ខ្លួនទេ បែរទៅជានាំគ្នាចាហានគៀបនៅក្នុងស្រុកក្រាំង ហើយធ្វើបាបរាស្ត្រទៅវិញ ដោយចោទថា អ្នកស្រុកក្រាំងសុទ្ធតែចូលដៃជាមួយទ័ពអាចារ្យស្វា រឹបអូសយកទ្រព្យសម្បត្តិរបស់អ្នកស្រុក ធ្វើបាបរាស្ត្រជាតិឯងខ្លាំងជាងទ័ពឈ្លានពានទៅទៀត អ្នកខ្លះចាប់កូនគេ អ្នកខ្លះចាប់ប្រពន្ធ អ្នកខ្លះយកទ្រព្យសម្បត្តិតាមអំពើចិត្តជញ្ជូនយកទៅធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន ៗ រាស្ត្រកើតក្ដៅក្រហាយមួយ

លើកទៀត អត់ទ្រាំមិនបាន ប្រមូលគ្នាជាកម្លាំងវាយតជាមួយទ័ពកផុសការ ដែលមានពពួកអន្សោមជាមេ ខ្លះស្លាប់ ខ្លះរត់រួចតែខ្លួន ទុកទ្រព្យសម្បត្តិដែលរឹបអូសទៅនោះចោលរគាត់រគាយ អ្នកខ្លះដែលយកទ្រព្យរបស់គេទៅ ក៏ត្រូវវិនាសហិនហោច ទៅតាមផ្លូវ ខ្លះយកទៅដល់ផ្ទះ ក្តៅក្រហាយមិនទ្រព្យលួចរាស្ត្រ, ក៏វិនាសទាំងទ្រព្យរបស់ឯងផ្ទាល់ថែមទៀត ។ ទើបរាស្ត្រនាំគ្នាទៅប្តឹងឧកញ៉ាក្រឡាហោមប៉ាងទៀត ។

**សូមរង់ចាំអាន**

“ភូមិតិរច្ឆាន” ឬ “ព្រឹត្តិការណ៍ ១៨ មេសា ១៩២៥” ជាឯកសារថ្មីតពីឯកសារ ១៨មីនា ១៩៧០ ជាឯកសារដែលរាស្ត្រខ្មែរសម្លាប់បារាំងនៅក្រាំងលាវ ដើម្បីទាមទារសេរីភាព ។

# ៨

## ប្រកាសចាប់ខ្លួន

ព្រះនរបតីទៅកំចាត់ទ័ពអាចារ្យស្វាហើយ ពួកអាចារ្យស្វា ដឹងថាទ័ពលួងមានបារាំងផង លើកមកដូច្នេះ ក៏នាំទ័ពរើជំរំចេញពីក្រាំង ។ ចំណែកអ្នកស្រុកដែលទៅប្តឹងពីពួកអន្សោមនិងពួកសេនាដែលទៅរឹបអូសយកអីវ៉ាន់ ក៏បានទៅដាក់បណ្តឹងក្រឡាហោមប៉ាង ។ ឯក្រឡាហោមប៉ាងបានឮដំណើរនេះភ្លាមមកការពារស្រុកក្រាំង កុំឲ្យទ័ពអាចារ្យស្វាចូលមកទៀតបាន ។

នៅថ្ងៃពុធ ៣ កើត ខែអាសាឍ ឆ្នាំជូតឆស័ក ព.ស ២៤០៨ សម្តេច ម៉ឹក បានត្រូវតែងតាំងឲ្យទៅឈរក្សាខេត្តខាងត្បូង ។ ទោះបីអ្នកមានថ្វីដៃកំចាត់ពួកអ្នកបះបោរឬអ្នកបដិវត្តន៍យ៉ាងណាហើយ ក៏ទ័ពអាចារ្យស្វានៅតែមានកំលាំងប្រព្រឹត្តសកម្មភាពវាយឆ្មក់ម្តង ៗ តែពេលណាក៏ដោយទ័ពអាចារ្យមិនសូវបានលទ្ធផលទេ ព្រោះថាទ័ពលួង ដែលមាន

ទ័ពបរទេសជាជំនួយផង ហើយមានសស្ត្រាវុធគ្រប់គ្រាន់ ។ អាចារ្យស្វាឃើញដូច្នោះ ទើបអាចារ្យស្វាហៅឈ្មោះ ស្នួ ដែលអាចារ្យស្វាបានតែងតាំងឲ្យធ្វើជាសុភាធិបតី មកបញ្ជាថា:

— លោកសុភាធិបតី ស្នួ ខ្ញុំហៅលោកមកនេះ ព្រោះខ្ញុំត្រូវការឲ្យលោកបំពេញបេសកកម្មមួយ ។ ខ្ញុំគ្មានសង្ឃឹមទៅលើនរណាម្នាក់ដែលឲ្យទុកចិត្តខ្ញុំទេ មានតែលោកម្នាក់ដែលអាចបំពេញបេសកកម្មនេះបាន ។

— បាទ ! ខ្ញុំស្ម័គ្រចិត្តជាដរាប

— យប់នេះ លោកនាំទាហានមួយក្រុម ចូលទៅខេត្តបាទីខាងត្បូង ព្រោះសម្តេច ប៉ុនអ៊ា ទើបតែមកឈរខែត្រនេះពីម្សិល ។ បើយើងសម្លាប់សម្តេច ប៉ុនអ៊ា បាន យើងមុខតែធ្វើសង្គ្រាមម្តងទៀតមានជ័យជំនះ ហើយបរទេសមុខតែអោនឹងថ្វីដៃយើងមិនខាន

សុភាធិបតី ស្នួ នាំទ័ពមួយក្រុមចូលទៅខេត្តបាទី បំរុងទៅធ្វើឃាតសម្តេច ប៉ុនអ៊ា ។ ព្រះនរបតីទ្រង់ជ្រាបពតិមាន



នេះហើយ ព្រះអង្គមានព្រះទ័យក្រោធពន្ទឹក ហើយព្រះអង្គលែងមានព្រះទ័យ ប្រោសប្រណីអាចារ្យស្វាទៀតហើយ លែងទុកព្រះទ័យថា អាចារ្យស្វាជាអ្នកដេញទ័ពបរទេសឈ្លានពានឲ្យចេញពីស្រុក ជាអ្នកស្រឡាញ់ជាតិទៀតហើយ ។ ព្រះអង្គយាងចុះយាងឡើងក្នុងដំណាក់ទ្រង់សញ្ជឹងថា :

" ពីមុន លោកវិជ្ជាសុខ បានប្រាប់ឯងថា អាចារ្យស្វាជាបាវព្រាវលោកនោះ វាគួបចិត្តតែនឹងយួននឹងបារាំងដែលចូលមកឈ្លានពានទឹកដីទេ ។ ឯងឃើញដូច្នេះ ក៏ទុកឲ្យវានៅការពារនៅកន្លែងនោះទៅចុះ ព្រោះឯងការពារនឹងយួននិងសៀមមិនឈ្នះ ទើបហៅបារាំងឲ្យគេមកជួយការពារៗ តាំងពីពេលដែលអាចារ្យស្វានេះ ថាទៅកាន់កាប់ទីនោះវាមិនឃើញដេញកាប់សម្លាប់យួនឯណា ឃើញតែសម្លាប់ខ្មែរ ដែលយកទៅឲ្យជួយត្រួតត្រា ដូចជាសម្តេច ប៉ុនអ៊ា ជាដើម ហើយមិនតែប៉ុណ្ណោះ ឥឡូវឮថា វាបែរទៅរកកំចាត់បារាំងទៀតដែលគេមកជួយ ។ អានេះ ទុកឲ្យវានៅយូរមិនបានទេ វា

មុខតែបន្តិចលាចលមកក្តីពេញហើយ កនឹងមកសម្លាប់ខ្លួនអញទៀតមិនខាន" ។

ព្រះអង្គទ្រង់ព្រះចិន្តាដូច្នេះ ទើបទ្រង់មានព្រះចិន្តាមួយថ្មីទៀត តាមសេចក្តីណែនាំរបស់បរទេសថា "ត្រូវធ្វើប្រកាសរកចាប់អាចារ្យស្វា" ។ ដូច្នេះទើបព្រះអង្គចេញប្រកាសឲ្យចាប់អាចារ្យស្វាយកមកធ្វើទោស ថា "បើនរណាចាប់អាចារ្យស្វាបាន នឹងឱ្យធ្វើចៅហ្វាយស្រុក" ។

ព្រះរាជប្រកាសនេះ បានត្រូវបិទព្រោងព្រាតគ្រប់ដំបន់ដែលអាចារ្យស្វាធ្លាប់ធ្វើសកម្មភាព។ បាឡាត់នោត ដែលមកឈរនៅខែត្រត្រាំង បានឃើញប្រកាសនោះ ក៏ខំស្វែងរកចាប់អាចារ្យស្វាដែរ តែមិនប្រទះសោះ ម៉្លោះហើយបាឡាត់ នោត បេះតែព្យាយាមរកឲ្យតែឮថាទៅកន្លែងណា គាត់ទៅរកកន្លែងនោះ ព្រោះចង់បានដំណែងចៅហ្វាយស្រុកស្វាយទង ។

យូរបន្តិចមក នៅលែងតាមដានរកចាប់អាចារ្យស្វា ហេតុនេះហើយធ្វើឲ្យអាចារ្យស្វានឹកតែក្នុងចិត្តថា បែបគេលែងរក



ចាប់ខ្លួនទើបអាចារ្យស្វាហៅ ដួង មកប្រឹក្សាថា

— ដួង! សេនាយើងដែលធ្លាប់ទុកចិត្តដូចយ៉ាងស្នងសិទ្ធ ជាដើម ដែលជាមនុស្សដែលក្រស្តចូលចិត្ត បានរត់ចូលនៅទីពល្លងវិញទៅហើយ ។ ឥឡូវនេះ ទីពល្លងដូចជាលែងនឹកនារកចាប់ពួកយើង យើងគិតកកងទ័ពថែមទៀត ដើម្បីចេញទៅតទល់ជាមួយទីពល្លងទៀត ។ តែពេលនេះយើងទៅកទីតាំងត្រាំងមិនបានទេ ព្រោះក្រស្តនៅត្រាំងបានដឹងថា ខ្ញុំរស់ក្បែរហើយ ។

— មែន! កុំលោកតែទៅសេពគប់ជាមួយស្រី ៣-៤ នាក់នោះ កុំអីមិនជាជុនជាបជល់ម្ល៉េះទេ ។ ឥឡូវបើលោកចង់ចេញផ្សេងរកសេនា ក៏ចេញទៅចុះ តែបើចេញទៅ តើយើងទៅតាំងទីជំរុំនៅឯណា ? លោកទៅគេណ្ឌខ្មែរនៅត្រាំងទៀតមិនបានជាដាច់ខាត តែចូលទៅមុខតែក្រស្តចាប់ទៀតមិនខាន ព្រោះអីរាជការបានពន្យល់ក្រស្តថាលោកជាមនុស្សធ្វើបាបក្រស្ត ធ្វើបាបតែខ្មែរ ជាមនុស្សក្បត់ជាតិ ជាមនុស្ស

ក្បត់រាជបល្ល័ង្ក ហើយក្រសួងថាក្បត់រាជបល្ល័ង្ក ក្បត់សាសនា នោះយើងនឹងការពារទ័ពបរទេសកុំឲ្យចូលមកជាន់ទឹកដីយើង យ៉ាងណាក៏ដោយ គេនៅតែឃោសនាថាយើងក្បត់ជាតិដែរ ។ ឥឡូវបើគេចោទមកដូច្នេះ តើលោកកទ័ពម៉េចនឹងកើត នរណាគេស្ម័គ្រចិត្តនឹងមកបំរើលោកទៀត ។

— ខ្ញុំនៅតែស្រឡាញ់ខ្មែរដដែល

— នៅតែលោកទេ ដែលថាលោកនៅតែស្រឡាញ់ខ្មែរ តែខ្មែរដែលគេបានឃោសនា គេបានអប់រំ គេបានពន្យល់ថា លោកធ្វើបាបខ្មែរ ហើយឥឡូវ គេទៅទូលលួងថា លោកចង់ទៅរកប្រាក់ថែមទៀត ហើយគេថា លោកចង់ទៅដណ្តើមរាជបល្ល័ង្កអង្គុយទៅលើទៀតផង ។

— គេចោទ ចោទទៅចុះ តែពេលនេះ យើងគិតកទ័ពមួយទៀតសិន បើសិនជាយើងកទ័ពបាន យើងត្រូវនាំគ្នាទៅតាំងបន្ទាយនៅឯស្វាយទងវិញ ។

— បើទៅនៅឯស្វាយទងបាន ព្រោះអ្នកស្រុកនៅកន្លែង



នោះ គេមិនជឿថាលោកអស់ពូកែទេ គេនៅគោរពខ្លាចលោកដដែល ។

និយាយគ្នាស្រុះស្រួលហើយ អាចារ្យស្វាក៏នាំទ័ពដែលនៅសេសសល់ខ្លះ ចេញទៅតាំងបន្ទាយនៅស្វាយទងវិញ ។ ពេលអាចារ្យស្វាចូលទៅដល់ស្វាយទងហើយ បានដើរបញ្ចុះបញ្ចូលរាស្ត្រ ។ អាចារ្យស្វាបានបញ្ជាឲ្យសេនាចូលទៅសម្លាប់រាស្ត្រខ្លះ អ្នករាជការខ្លះ ដែលប្រឆាំងនឹងគោលគំនិតរបស់លោក ដើម្បីឲ្យដឹងថ្វីដៃរបស់ខ្លួន ។ មុននឹងទៅធ្វើបន្ទាយនៅឯជ្រោះពក អាចារ្យស្វាបានឲ្យសេនានៅសម្លាប់ទាំងខ្មៅ ១ និងស្រីនិប ១ បានដូចបំណង ទើបនាំគ្នាទៅក៏តាំងជាបន្ទាយ រកស្បៀងអាហារខ្លះទុកសម្រាប់ការពារពេលអត់ឃ្លាន និងពេលធ្វើសឹកជាមួយបរទេស ។

# ៩

## អាចារ្យស្វាអស់ជីវិត

សេនាខ្លះចេញទៅរកស្បៀង ខ្លះចេញទៅបញ្ចុះបញ្ចូលរាស្ត្រឲ្យស្រឡាញ់ចូលធ្វើជាសេនាទ័ពអាចារ្យស្វា ឯរាស្ត្រខ្លះនៅឮថា អាចារ្យស្វាពូកែម្ល៉េះហើយក៏ស្ម័គ្រចូលធ្វើជាសេនាទៅ តែមានខ្លះទៀត នៅចាំមិនភ្លេចប្រកាស ដែលព្រះនរបតីទ្រង់ចេញរកចាប់រូបអាចារ្យស្វា ។

ប្រកាសចាប់ខ្លួនអាចារ្យស្វា ចេញបិទព្រោងព្រាតនៅតាមកៀនកោះក្នុងស្រុកទ្រាំង តែគ្មានរាស្ត្រណាម្នាក់រកចាប់អាចារ្យស្វាទេ ។ ពេលនោះស្នងសិទ្ធ ដែលធ្លាប់បានធ្វើសេនារបស់អាចារ្យស្វាដែរនោះ បានលាក្រឡាហោម ម៉ាំង ចេញទៅរកអាចារ្យស្វាម្តង ក្រែងលោកសេនាបានធ្វើជាចៅហ្វាយស្រុក ។

— លោក! ខ្ញុំបាទ ដឹងគំនិតអាចារ្យស្វា ដឹងនយោ-



បាយអាចារ្យស្វា ខ្ញុំគិតទៅចាប់អាចារ្យស្វាម្តង

— ទៅម្នាក់ឯង ?

— បាទ! គិតទៅម្នាក់ឯង បើទៅគ្នាច្រើន ក្រែងអាចារ្យស្វាសង្ស័យ ។ បើខ្ញុំទៅម្នាក់ឯង ទៅបោកតាមគំនិតរបស់ខ្ញុំបាទ

— បើតាមយោបល់ខ្ញុំ លោកចាំតែធ្វើការជាមួយខ្ញុំឲ្យបានស្រួលទៅ ហើយបើសម្លាប់អាចារ្យស្វាបាន ឆារចៅហ្វាយស្រុកស្វាយទងនោះ មិនធ្លាក់ទៅលើនរណាក្រៅពីយើងទេ ។ តែនេះ ខ្ញុំគ្រាន់តែបង្ហាញគោលលោកខ្លះ ស្រេចតែលោកគិតទៅទៀតចុះ ។

ឯអាចារ្យស្វាតាំងបន្ទាយនៅលើភ្នំជ្រោះពកនោះ ស្មានថាបានសុខមួយគ្រាហើយ តែមិនដូច្នេះ រឹងរឹតតែជួបសេចក្តីស្លាប់កាន់តែឆាប់ឡើង ។ ពេលដែលអាចារ្យស្វាកំពុងតែដើរត្រួតមើលសេនាធ្វើបន្ទាយ ស្រាប់តែមានសេនាដួង ចូលទៅខ្សឹបប្រាប់អាចារ្យស្វាថា :

– លោកពេលមុននេះបន្តិចមានអ្នកស៊ើបការណ៍សម្ងាត់របស់យើង បានឲ្យការណ៍ថា មានជ្វាម្នាក់ពូកែខាងសិល្បមន្តអាគមន៍ឈ្មោះ ចាញ់-អ៊ិត បានចូលដល់ជ្រោះពកនេះហើយ ។ តាមអ្នកស្រុកនិយាយថា មកនេះមិនមែនដើររកមើលពេទ្យ ឬកិច្ចការអ្វីផ្សេងទៀតក្រៅពីចាប់លោកទេ សូមលោកប្រយ័ត្ន

– ចាញ់ អ៊ិត ! ពិតជាជ្វាមែន ?

– ពិតមែន

– ដូចជាមិនដែលល្អ ៗ ដូងម៉េចក៏បេះ ជានៅឯព្រៃង ឯណោះ មានប្រកាសរកចាប់ពួកយើង ទើបយើងមកស្វាយទង ក្រែងបានសុខ តែនេះហាក់ដូចជាកាន់តែជួបសេចក្តីលំបាកទៅទៀត ៗ ឥឡូវនេះយើងគិតទៅផ្លូវណាទៀតឆ្នំខ ?

– ខ្ញុំមិនដឹងគិតផ្លូវណាទេ សុខចិត្តតែតាមលោក នាំទៅណាក៏ទៅតាមដែរ

– ឥឡូវនេះ រាជការកំពុងតែរកចាប់ ហើយក្រស្តភាគ



ច្រើនដែលគេលែងទុកចិត្តយើង ព្រោះក្រស្តបានឃើញប្រកាសហ្វូងបិទពេញតែភូមិស្រុក ៗ

– មើលសេនា ឆ្នំខ ជួយគិតផងមើល ៗ

– បើឲ្យខ្ញុំថា មានតែយើងចេញពីទីនេះឲ្យរួចតែមួយគ្រាសិនទៅ ព្រោះជ្វាកខ្លាំងពូកែណាស់ដែរ ហើយវាកំពុងតែមករកចាប់លោកហើយ ៗ

– យើងគេចទៅចេះតែបាន តែមុននឹងស្លាប់ត្រូវសម្លាប់យួនឲ្យបានសិនដែរ តែខ្ញុំចង់ល្បងមើលសិល្បវាបន្តិចសិន ៗ

– កុំអាលលោកប្រយ័ត្នគ្រោះដល់ខ្លួន ហើយឯការសម្លាប់យួនដូចជាពិបាក បើក្រស្តខ្មែរលែងចូលមកជួយទៅហើយ ហើយឥឡូវពួកយើងមានចំនួនតិចផង ៗ

– ពិតមែន តែយើងត្រូវរកមធ្យោបាយបញ្ចុះបញ្ចូលក្រស្តស្វាយទងម្តងសិន ៗ ខ្ញុំដឹងការណ៍មួយថា នៅស្វាយទងមានតាម្នាក់ ដែលក្រស្តស្រឡាញ់ដែលក្រស្តទុកចិត្ត បើយើងទៅហៅតានោះមក មុខតែក្រស្តចូលមកជាមួយយើង

ច្រើនមិនខានឡើយ ។ ជូនឯងដឹងទេ តាឫស្សី ! តាប៊ូកស្រួ ស្រឡាញ់ណាស់

— បានឮឈ្មោះគាត់ដែរ តែក្រែងគាត់មិនចូលជាមួយណា៎លោក !

— សាកមើលសិនទៅណា៎ ! ដូច្នេះខ្ញុំសូមឲ្យសេនាជួនឯងនាំគ្នាទៅឥឡូវនេះទៅអញ្ជើញលោក តាឫស្សី ឲ្យមកជួបខ្ញុំ ចាំខ្ញុំនិយាយបញ្ចុះបញ្ចូលគាត់ ។

— សេនា ដួង មិនបង្អង់យូរឡើយ ទំទៅរកជួបលោកតា ឫស្សី តែចេញទៅចាំនគរប្រមល់ ព្រោះខ្លាចជួបនឹងទ័ពដែលដេករកចាប់អាចារ្យស្វាផង ក្រែងជួបនឹងផ្កាផង តែពាស់លើទៅឆ្ងាយប្រើហើយសេនា ដួង ចេះតែទៅតាំងប្រថុយ ។ សេនា ដួង ចេញទៅបានជួបនឹងលោកតា ឫស្សី មែនហើយ ពាក់ទងជាមួយលោកតា ឫស្សី តាមលំនាំដែលអាចារ្យស្វាបានបញ្ជា ។ សន្ទនាគ្នាបន្តិចសេនា ដួង ក៏នាំលោកតា ឫស្សី ហើយ ទំនិយាយបញ្ចុះបញ្ចូលលោកតា ឫស្សី ឲ្យចូលទៅតាម



ផែនការ របស់ខ្លួនដែលបានគ្រោងទុកមកថា :

— លោក ! ខ្ញុំអញ្ជើញលោកមកនេះ ព្រោះខ្ញុំចង់លើកតម្កើងលោកឲ្យមានឋានៈខ្ពស់ សមទៅតាមសេចក្ដីគោរពរបស់អ្នកស្រុក ហើយលោកក៏មាននយោបាយបន្តិចដែរ ។ ខ្ញុំមានចិត្តចង់ឲ្យលោកធ្វើជាមេទ័ពស្រួចទៅឈររក្សាស្រុកស្វាយទង ដើម្បីជួយការពារកុំឲ្យយួនចូលមកលុកលុយស្រុកស្វាយទងបាន មើលលោកពេញចិត្តនឹងតំណែងនេះឬទេ ?

ពេលដែលអាចារ្យស្វានិយាយបញ្ចុះបញ្ចូល លោកតា ឫស្សី នឹកតែក្នុងចិត្តថា (មុខហ្នឹងហើយដែលព្រះនរបតីប្រកាសរកចាប់ខ្លួន មិនអីទេអញគិតរកមធ្យោបាយចាប់អាចារ្យស្វា ដូច្នេះអញគិតតស៊ូមើលសិនទៅ ចាំថ្ងៃណាមួយសឹមអញចាប់យកទៅជូនពជការហើយថ្វាយស្រុកទំនងបានមកអញ មិនខានឡើយ) ។ អាចារ្យស្វានិយាយជាមួយលោកតា ឫស្សី ជាច្រើនមានបញ្ហាផងលើកតម្កើងផង តែលោកតា ឫស្សី ដែលជាអ្នកលោកបុណ្យបែរជាធុញទ្រាន់នឹងសំដី អាចារ្យស្វាឥតមេ-

មា តែពេលនោះគាត់មិនបានបញ្ចេញអាការៈ ឲ្យអាចារ្យស្វាដឹងថាគាត់មិនពេញចិត្តទេ ព្រោះអីគាត់ទៅក្នុងកណ្ដាប់ដៃគេ ទើបគាត់បែរជាឆ្លើយថាៈ

— គំណែងដែលលោកឲ្យខ្ញុំនេះ ខ្ញុំពេញចិត្តណាស់ តែខ្ញុំជួបជាបេះតែបារម្ភក្រែងធ្វើការមិនបានសម្រេច ព្រោះខ្ញុំមានវ័យចាស់បន្តិចហើយ

មិនអីទេលោក ឲ្យតែលោកទទួលចុះ ខ្ញុំឲ្យលោកទៅនៅគ្រប់គ្រងរក្សាស្រុកស្វាយទងភ្នាម ។

—លោកតា ឫទ្ធិ ឆ្លើយនេះគ្រាន់តែឲ្យមានការពាក់ទងជាមួយអាចារ្យស្វា ព្រោះលោកមានការមួយយ៉ាងសំខាន់ ហើយយ៉ាងស្ងាត់ផង ។ លោកនិយាយបណ្ដើរនឹកទៅឃើញកាំ-ភ្លើងពួកម៉ាកម្នាក់ ដែលធ្លាប់តែយកទៅបាញ់សត្វនៅក្នុងព្រៃ មានពេលខ្លះយកទៅបាញ់ចោរប្លន់ផង ។ និយាយស្រុះស្រួលគ្នាហើយ លោកតា ឫទ្ធិ លាអាចារ្យស្វាទៅលំនៅវិញ តែការស្ងាត់របស់គាត់មិនបោះបង់ចោលឡើយ ។ លោក



មកដល់ផ្ទះវិញ មិនទាន់ទៅផ្ទះភ្នាមទេ លោកធ្លៀតទៅរកជួបពួកម៉ាកដែលមានកាំភ្លើងស៊ិន ។ លោកទៅរកជួបមិត្តនោះបានជួបចំណាន់ឯលោកតា យិន ឃើញលោកតា ឫទ្ធិ មកដោយខុសកាលជួបប្រះ នឹកសង្ស័យទើបសួរថាៈ

— មកពីណាថ្ងៃណេះ ឫទ្ធិ ?

— មានការស្ងាត់ណាស់

— ការអីទៅឡើង ! មកលើផ្ទះសិនទៅ !

លោកតា យិន នាំតា ឫទ្ធិ ចូលទៅក្នុងបន្ទប់ស្ងាត់ ទើបតា ឫទ្ធិ និយាយរឿងដែលអាចារ្យស្វា អញ្ជើញគាត់ឲ្យទៅជួបនៅឯក្នុងបន្ទាយជ្រោះតាក តែទំបំផុតគាត់ទាំងពីរបែរជាគិតរកមធ្យោបាយ ចាប់អាចារ្យស្វាវិញ ។ លុះនិយាយគ្នាស្រុះចិត្តជាធ្លុងមួយហើយ លោកតា យិន និងតា ឫទ្ធិ ទៅបបួលពួកម៉ាកបាន ៤-៥ នាក់ ប្រុងនឹងទៅចាប់អាចារ្យស្វាទាំងរស់យកទៅថ្វាយព្រះនរបតី ។

ឯទ័ពយួនដែលចាញ់ដៃអាចារ្យស្វាពីពេលមុននោះ លុះ

ដឹងដំណឹងថា ទ័ពអាចារ្យស្វាមកតាំងបន្ទាយនៅបន្ទាយកំព្រោះពក មានសេចក្ដីក្រេកអរណាស់ ទើបចាត់គ្នាឲ្យទៅព័ទ្ធបាញ់អាចារ្យស្វានិងពួកទ័ពដែរ ។ ឯទ័ពយួនលើកទ័ពទៅព័ទ្ធទ័ពអាចារ្យស្វាមិនចុះទេ ព្រោះទ័ពអាចារ្យស្វានៅបណ្ដាក់គ្នាយាមល្បាតម៉ត់ចត់ណាស់ ។ អ្នកយាមបានដឹងថា ទ័ពយួនមកព័ទ្ធជុំបោះទើបអ្នកយាមនៅប្រាប់អាចារ្យស្វាថា :

— លោក ! ប្រុងប្រយ័ត្ន ទ័ពយួនប្រុងចូលចាប់លោកទៀតហើយ យើងគួរតែចេញពីបន្ទាយជ្រោះពកនេះសិនប្រញាប់ឡើងលោក វាមកដល់ខ្លួនហើយ

មើលសេនា ដូច ប្រុងប្រយ័ត្នមែនទែនឡើង នាំទ័ពយើងចូលទៅក្នុងរូង ហើយនាំគ្នាទៅក្នុងរូងទៅ តែមុននឹងចេញពីក្នុងរូង ត្រូវឲ្យគ្នាយើងទៅមើលទ័ពយួនសិន ក្រែងវានៅមានពួនទៅកន្លែងនោះ

គ្រាន់តែចប់សន្ទនាគ្នាភ្លាម អាចារ្យស្វានិងទ័ពក៏នាំគ្នាចូលក្នុងរូង ហើយយកបន្ទះក្ដារដែលជាកន្លែងដើរក្រោមគ្រប



ពីលើ យ៉ាងស្រួលល្អមិនកុំឲ្យនរណាសង្ស័យបាន ។ ឯទ័ពយួនចូលទៅដល់ក្នុងបន្ទាយ រកមើលទ័ពអាចារ្យស្វាមិនឃើញម្នាក់សោះ ហាក់ដូចជានាំគ្នាផ្លែល ។ ព្រោះខ្លាចទ័ពអាចារ្យស្វានាំគ្នាបំបាំង ។ លុះមិនឃើញទ័ពអាចារ្យស្វា ទើបមេទ័ពយួនបញ្ជាឲ្យដកទ័ពថយភ្លាមដែរ ។ ឯទ័ពអាចារ្យស្វា ដែលលួនចូលទៅក្នុងរូងនោះតម្រង់ទៅស្វាយទង ព្រោះទុកសង្ឃឹមថានឹងបានជួបទ័ពលោកតា ឬ ស្រាប់តែចេញមកពីរូង ទ័ពយួនក៏លើកទៅដល់ដែរ ពេលនោះយួនដេញបាញ់អាចារ្យស្វា ឯអាចារ្យស្វានាំទ័ពទៅរកទ័ពលោកតា ឬ តែត្រូវទ័ពតា ឬ ដេញបាញ់រត់រកតែកាយមិនទាន់ ។

ទ័ពអាចារ្យស្វាវិលក្បួន រត់ទៅណេះក្រែងជួបយួន រត់ទៅនាំងណោះក្រែងជួបទ័ពតា ឬ ។ ចំណែកទ័ពយួនដងជានៅស្វាយទងមានបលជាមួយក្រុមដែរ មិនហ៊ានចូលទៅទេ ព្រោះខ្លាចដៃខ្មែរស្នេហាជាតិមែនទែន ។ ជាឱកាសល្អទ័ពតា ឬ ដេញតាមទ័ពអាចារ្យស្វា ប្រកិត ។ មិនឃ្លាត

ឆ្ងាយពីគ្នាឡើយ ។ ឯកូនទ័ពអាចារ្យស្វា គេបែកគ្នាអស់នៅសល់តែអាចារ្យស្វាម្នាក់ និងសេនា ជួន នៅជាប់ជាមួយគ្នា អាចារ្យស្វាមិនដឹងជាគេទៅណា ក៏គេចូលទៅក្នុងវត្តព្រះធាតុ ដើម្បីយកព្រះពុទ្ធជាទីពឹង ឬ យកព្រះសង្ឃជួយអង្វរតា ប៊្បី និងតា យិន ។ អាចារ្យស្វាចូលទៅក្នុងវត្ត ហើយពួនត្រង់នេះមិនសុខ ពួនត្រង់នោះមិនសុខ ទើបចូលទៅក្នុងព្រះវិហារ ព្រោះខ្លាចកាំភ្លើងតា យិន។ អាចារ្យស្វាភ័យណាស់ថា ពេលនេះមើលទៅជីវិតទីបំផុតនៅត្រង់នេះហើយ ទើបឡើងទៅអង្គុយជាមួយព្រះពុទ្ធរូបលើបល្ល័ង្ក នៅតែមិនសុខមិនស្ងប់ទើបក្បាលចូលទៅក្នុងហង្ស្យកព្រះពុទ្ធរូប តែនៅតែបិទបាំងមិនជិតទៀត សំឡឹងមើលជុំវិញ ឃើញធ្នឹមព្រះវិហារវែងដូចស្រួល ទើបអាចារ្យស្វាចុះពីបល្ល័ង្កព្រះ ហើយតាប់សសរឡើងទៅពួននៅលើធ្នឹមព្រះវិហារ ។

ទ័ពតា ប៊្បី ដេញទៅដល់វត្តព្រះធាតុ មានគេឲ្យការណ៍ថាទ័ពអាចារ្យស្វាគេចូលវត្តព្រះធាតុ ក៏នាំគ្នារកមើលពេញតែ



ក្នុងវត្តអារាម ។

ទ័ពតា ប៊្បី រកមើលក្នុងវត្តព្រះធាតុមិនឃើញ រៀបតែនាំគ្នាចេញពីវត្តទៅវិញ ស្រាប់តែនឹកឃើញរឿងអ្វីមួយតា ប៊្បី ក៏ឲ្យមនុស្សចូលទៅក្នុងព្រះវិហារ ។ ពេលនោះបើអាចារ្យស្វាមានគ្រឿងប្រហារទៅជាមួយដូចជាស្នាព្រួញជាដើម មុខជាបាញ់ទ័ពតា ប៊្បី បានច្រើនព្រោះថាទ័ពតា ប៊្បី ដើរចូលនៅក្នុងព្រះវិហារ មិនមានចិត្តគិតថាអាចារ្យស្វា នៅលើធ្នឹមព្រះវិហារទេ ហើយពេលនោះទៀត បើសិនអាចារ្យស្វាស្លៀកពាក់ខ្មៅសុទ្ធ ក៏មិនអាចមើលទៅឃើញដែរកម្មផល ពេលដែលអាចារ្យស្វាតាប់ឡើងសសរព្រះវិហារមិនបាន ទើបអាចារ្យស្វា បែរទៅយកវត្ថុព័ន្ធបង្កុះព្រះដែលគេទើបយកទៅថ្វាយ ព្រះអង្គ ទៅចងធ្វើជាខ្សែលីងជើង ដើម្បីឲ្យងាយតាប់ឡើងតាមសសរ ឆាប់ឡើង ដល់ទៅលើធ្នឹមអាចារ្យនឹកឃើញថាពណ៌វត្ថុព័ន្ធខុសពីពណ៌ខោអាវ ដូច្នេះហើយបានជាទ័ពតា ប៊្បី មើលឃើញច្បាស់ ៗ លុះឃើញថាអាចារ្យស្វា

ទៅពួននៅលើធ្នឹម ទើបតា ប៊ី ចុះទៅជំរាបតា យ៉ិន វិញថា ៖

– លោក ! អាចារ្យស្វានៅលើធ្នឹមព្រះវិហារ

– គ្រាន់តែឮភ្លាម តា ប៊ី ឲ្យអ្នកស្រុកចាំព័ទ្ធជុំវិញព្រះវិហារ ឯតា យ៉ិន ប្រុងកាំភ្លើងស្រេចជាមួយតា ប៊ី ។ តា ប៊ី ចូលទៅដល់ក្នុងវិហារ ក៏ហៅអាចារ្យស្វាឲ្យចុះ

– ចុះមកអាស្វា !

អាចារ្យស្វាមិនតបថាដូចម្ដេចឡើយ ។ តា ប៊ី ហៅពីរ បី ដង អាចារ្យស្វានៅតែមិនចុះ តា ប៊ី លើកកាំភ្លើងតម្រង់ គេះកៃកាំភ្លើងឮតែផាំង សំរែកមួយក៏បញ្ចេញស្នើគាដែរ ។ អាចារ្យស្វាធ្លាក់ពីធ្នឹមព្រះវិហារមកដី ។ អាចារ្យស្វារៀបដាច់ខ្យល់ បានបន្ទឹពាក្យថា :

⊥ « ហេតុតែលោកបុណ្យសក្ដិ សុខចិត្តសម្លាប់ជាតិឯង» ពេលនោះ អ្នកដែលឈរនៅជុំវិញសពអាចារ្យស្វាមានចិត្តស្រងូតស្រងាត់ អ្នកដែលលោកបុណ្យសក្ដិ គ្រាន់តែភ្ញាក់ខ្លួន ឯអ្នកដែលជឿតាមគេ ដើរចេញពីកន្លែងនោះ ទោះ



ដំបង ហោះកាំបិតចោល ព្រោះតូចចិត្តនឹងសេចក្ដីពន្យល់របស់គេ ។

✿

**សូមកុំភ្លេច**

បន្ទាប់ពីអាចារ្យស្វាទៅនឹង

មានចេញ **ពោធិកំបោរ**

ទៀតជាឯកសារដែលទាក់

ទងនឹងប្រវត្តិសាស្ត្រខ្មែរ

# ១០

## គូព្រេងមិនព្រាត់

បន្ទាប់ពីអាចារ្យស្លាស្លាប់ទៅ អ្នកដែលគេលោកបុណ្យសក្តិសប្បាយទៅ អ្នកដែលជឿតាមតែគេប្រើ ដោយមិនបានពិចារណា មានតែសេចក្តីស្តាយ ។ ចំណែកកស្ត្រវិញ ដែលជាអ្នកប្រកបរបរកសិកម្ម គ្មានគ្រឿងសស្ត្រាវុធ គិតតែសប្បាយនឹងកិច្ចការ ព្រោះថា បើគ្មានចលាចល គ្មានសឹកសត្រូវគេអាចធ្វើការបានយ៉ាងស្រួល ។ ពីពេលនោះ អ្នកដែលស្រឡាញ់ជាតិ អ្នកដែលមិនពេញចិត្តនឹងការត្រួតត្រាបរទេសកាន់តែរណោះទៅជាលំដាប់ដែរ ហើយអ្នកដែលលបរៀនមន្តអាគម ក៏ត្រូវគេចាប់ ទៅទៀត ។

យើងត្រឡប់មើលទៅប្រជាកស្ត្រនៅជុំវិញក្នុងដែលសប្បាយរកស៊ីប្រៀបពុំបាន ហើយឆ្នាំនេះលែងមានទ័ពយួនចូលមកតាដៅ លែងមកកៀរស្តូរ លែងមកធ្វើបាបប្រជាកណ្ដ



កស្ត្រខែទៀតជួយទៅសម្លាប់កស្ត្រខែរគ្នាឯង ។ សេចក្តីសប្បាយគឺឆ្នាំនេះកស្ត្រធ្វើស្រូវបាន ហើយបាននៅជាសុខ ។

ពេលល្ងាច គេឃើញបុរសស្ត្រីមួយគូអង្គុយជជែកគ្នាលេង

— ម៉េចមិនក្បត់ជាតិ ព្រោះយើងទៅដេញសម្លាប់រកចាប់អ្នកស្រឡាញ់ជាតិ ។ បើយើងរកចាប់អ្នកស្រឡាញ់ជាតិ យើងទុកដូចជាក្បត់ជាតិឯងទៅវិញ —

— កាលនោះ យើងជឿតែតាមគេ យើងស្មានថាគេក្បត់ជាតិ ។ តែធ្វើកាលនោះ ធ្វើក្នុងឋានៈនៃយើងជាអ្នកបំរើជាតិ មិនមែនយើងបំរើមនុស្សម្នាក់ទេ ដូច្នេះហើយបានជាយើងដល់ពេលស្លាប់ច្រើនផង យើងចេះតែគេចផុត ។ អូនឃើញទេ ពេលដែលអូនចាប់បងទៅ បងស្មានថាស្លាប់ហើយ បែរជាអាចារ្យស្លាទៅជួយ

— រួចបើអាចារ្យស្លាទៅជួយហើយ ម៉េចក៏បងនៅតែថាគាត់ក្បត់ជាតិទៀត ?

– ពីនោះហើយ ដែលបងលែងទៅរកចាប់អាចារ្យស្វា រហូតដល់គេសម្លាប់លោកចោល បើសិនជាបង មិនដឹងការពិតទេនោះ ម្ទេះបងនៅតែប្រព្រឹត្តអំពើនេះ រហូតដល់សម្លាប់អាចារ្យស្វាខ្លួនឯង–

– មែនបង ! តែគេមិនពេញចិត្តនរណាម្នាក់ គេតែងថានរនោះ "ក្បត់" ដូចយើងវាយឆ្កែល្អស្លាប់ហើយចោទ មួលប្រកាច់គ្នាថា "ឆ្កែឆ្កួត" ។

គេហដ្ឋានមួយខ្នង នៅក្បែរជើងភ្នំ កំពុងតែមានការតុបតែងលំអរុក្ខជាតិ ទីងមានរោងពិសេសមួយនៅក្បែរផ្ទះធំ ៗ ថ្ងៃរសៀលបន្តិច ឃើញក្បួនមួយតូចហែចូលទៅកាន់ផ្ទះនោះ ដោយមានក្មេងមួយវង់តូចដើរយោងកំដរពីមុខៗ ឯមនុស្សដែលជាតួឯកក្នុងពិធីហែក្បួននេះ មានពួកម៉ាកបាំងច្រៀងផង ។

ក្បួនហែទៅដល់គេហដ្ឋាននោះហើយ ទើបចូលទៅក្នុងរោងមួយតូច ដែលគេធ្វើទុកសំរាប់ឲ្យកូនកំលោះ ៗ ពិធីតាមប្រពៃណីការរៀបការប្រព្រឹត្តទៅរហូតដល់ពេលសំពះបង្វិលដៃ ។



ពួកម៉ាក, មិត្តដែលបានរួមកុំការគេស្មឹកុំបលនាទីពីអាចារ្យស្វា បានទៅជួយអបអរសាទរទាំងអស់គ្នាតែពិសេសគេឃើញនាងរឿន ដែលជាមិត្តជិតស្និទ្ធ បានចូលទៅបាចផ្កាស្លា ហើយបានចងអំបោះឲ្យគូស្វាមីដែរ ។ លុះគួចខ្សែរបំណងដៃ ហើយនាងរឿនបន្ទឹថា

– សូមឲ្យបានជួបតែនិងសុភមង្គល ហើយស្មោះស្ម័គ្រតែនឹងប្រទេសជាតិ ។ មែន ! គេជួបគ្នាមែន ! នេះបានជាគូព្រេងមិនព្រាត់មែន !

គូស្វាមីភរិយា ទទួលជាសាធុព្រមគ្នា ។

គូស្វាមីភរិយា ចាំងពីពេលនេះ មិនដែលមានពាក្យធ្ងន់ទៅរកគ្នាឡើយ ហើយទំនៃរកប្រកបការងារជាអ្នកស្រែតាមធម្មតា ហើយ និងជួបការពោះសុខទុក្ខក្រស្ដ ដែលនៅក្នុងភូមិជាមួយគ្នា ។ ថ្ងៃមួយគ្រួសារនេះត្រឡប់មកពីធ្វើការឯស្រែចរិកោតបាយ ហើយ ចុះទៅអង្គុយលេងនៅក្រោមដើមឈើសំណេះសំណាល រឿងនេះ រឿងនោះ ហូតមករឿងផ្ទាល់ខ្លួនថា :

— បង ! អូនស្មានថា យើងលែងបានជួបគ្នា ព្រោះគឺជីវិតយើងនៅតែក្នុងកណ្ដាប់ដៃមច្ចុរាជច្រើនផងណាស់

— មិនអីទេអូន អូនចាំច្បាស់ថា តែយើងមិនក្បត់ចិនជាតិ ទេវតាមុខតែជួយយើងជាដរាប ។

— គូស្វាមី តែងតែមកជាដៃគ្នាលេងនៅកន្លែងនេះជាដរាប ៗ មិនយូរប៉ុន្មានគ្រួសារស្នេហ៍សិទ្ធមានគ្នាកើតរាល់ឆ្នាំ ហើយរស់នៅជាសុខសាន្តរហូតដល់ចាស់រៀងៗខ្លួន ។

**ចប់ដោយបរិបូរណ៍**